ខ្មែរប៉ុស្តិ៍
ឆ្នេរខាងកើត
THE KHMER POST
EAST COAST
The Cambodian-American Biweekly News
Email : Khmerpostusa@gmail.com
Call : (267) 253-3947
VOLUME 04 ISSUE 64 July 30th - August 12th 2010

## មាតិការឿង ទំព័រ

១- ឃ្មួនចង់ជណ្តើមរ៉ែមាសពីអូស្រ្តាលី..........ទំព័រទី០៣
២- អវត្តមាន សម រង្ស៊ី ជះឥទ្ធិពលធ្ងន់ធ្ងរ..........ទំព័រទី០៤
៣- ប្រវត្តិព្រះអាចារ្យ ហែម ចៀវ (ត) និងព្រះគ្រូ ទីម សាខន..........ទំព័រទី០៥
៤- The Cambodia Daily និង អ្នកនយោបាយ ឬអ្នកលេងល្បែង..........ទំព័រទី០៨ &១៣
៥- អាថ៌កំបាំង និងសិល្បៈនៃជីវិត..........ទំព័រទី១៤
៦- នាទីប្រវត្តិសាស្រ្តខ្មែរ និងនិងនាទីព្រះសាសនា..........ទំព័រទី១៥
៧- ស្រ្តីខ្មែរដំបូងបង្អស់ដែលធ្វើដំណើរពីប្រទេសបារាំង(ត)..........ទំព័រទី១៦
៨- ហោរាសាស្រ្ត និងសោភ័ណភាព..........ទំព័រទី១៧

# សកម្មភាពសហគមន៍ដោយរូបភាព

**•••សមាជិកសមាគមន៍ខ្មែរ**ប្រមាណ៥០នាក់ បានមកចូលរួមស្តាប់សេចក្តីរាយការណ៍ប្រចាំ ឆ្នាំ





របស់គណៈកម្មាធិការប្រតិបត្តិនៅទីស្នាក់ការផ្លូវលេខ៥ ហ្វីឡាដែលហ្វៀ ខាងជើងកាលពីថ្ងៃសៅរ៍ ទី២៤ ខែកក្កដា កន្លងទៅនេះ ។

**•••នៅវត្តសុរិយា រង្សី** ខាងជើងហ្វីឡាដែលហ្វៀមានធ្វើកិច្ចប្រជុំបញ្ចប់វគ្គសិក្សា៥សប្តាហ៍របស់កម្មវិធី ភីក (PEAK) ដែលជាកម្មវិធី "ពង្រីកឋាមពលគ្រួសារដោយចំណេះដឹង"រៀបចំឡើង ដោយ MHASP ។ លោកស្រីចាន់ ថា មារី តោ លោកស្រី ភោគ អឿង នឹងលោក សរិត ប៉ែន បានទទួលសញ្ញាបត្របំពេញវគ្គសិក្សាថា ថ្ងៃទី២២ ខែកក្កដាឆ្នាំ២០១០នោះ ។

**•••នៅសួនឧទ្យាន ក្បែរវត្តព្រះពុទ្ធរង្សី** មានយុវជនស្ម័គ្រចិត្តមួយចំនួននាគ្នាសំអាតថ្នល់ នឹងសួនឧទ្យាន ដែលជាទីមានកុមារ នឹងគ្រួសារខ្មែរជាច្រើនចូលចិត្តទៅកំសាន្តនៅទីនោះ មានទាំងលេងកីឡា **(តទៅទំព័រទី ១១)**

# កុងស៊ុលខ្មែរនៅហ្វីឡានឹងបើកនៅខែកញ្ញាខាងមុខនេះ



**ដោយ : អ៊ុច លៀម**

•••យោងតាមប្រភពព័ត៌មានច្បាស់ការមួយពីសកម្មជនរបស់សាខាគណ-បក្សប្រជាជនកម្ពុជា ប្រចាំរដ្ឋផែនស៊ីវ៉ៃនៀរ៉ា (PA) បានឱ្យដឹងថា គណបក្សនេះនឹងបើកកុងស៊ុលខ្មែរជាលក្ខណៈផ្លូវច្បាប់មួយនៅក្នុងអំឡុងខែកញ្ញាខាងមុននេះ នៅក្នុងទីក្រុង ហ្វីឡាដែលហ្វៀប្រយោជន៍សម្រាប់សម្រួលដល់កិច្ចការមួយចំនួន ដែលពលរដ្ឋ ឬក៏ខ្មែរ-អាមេរិកាំងត្រូវការពឹងពាក់ពុំនាក់ អាស្រ័យ ដោយក្នុងនោះ ក៏មានកិច្ចការផ្នែកការទូតមួយចំនួនផងដែរ ។

លោក សុខ សារឿន ឬមានឈ្មោះម្យ៉ាងទៀតថា PETER ជាអនុប្រធានសាខាគណបក្សប្រជាជនកម្ពុជា និងអនាគតជាមន្ត្រីអគ្គកុងស៊ុលខ្មែរប្រចាំទីក្រុងហ្វីឡា-ដែលហ្វៀ បានឆ្លើយបំភ្លឺចំពោះសំនួរ "ខ្មែរប៉ុស្តិ៍" កាលពីថ្មីកន្លងមកនេះថា : ទីក្រុងហ្វីឡាដែលហ្វៀ ពិតជាបើកកុងស៊ុលខ្មែរ នៅខែកញ្ញាខាងមុខនេះមែន ប៉ុន្តែចំពោះកាលបរិច្ឆេទពិតប្រាកដ គេនៅពុំទាន់បានដឹងឡើយ ហើយទីកន្លែងជាក់លាក់នេះក៏នៅពុំទាន់បានកំណត់ទេ ដោយគ្មានតែដឹងថា មានទីតាំងស្ថិតនៅផ្នែកខាងជើងនៃទីក្រុងហ្វីឡាដែលហ្វៀតែប៉ុណ្ណោះ ។ លោក សា រឿន បន្តថា : លោកឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស ហោ ណាំហុង. **(តទៅទំព័រទី ០៦)**



ដសុខ សារឿន

# ការឃាត់ខ្លួនលោកស្រី មូរ សុខហួរ ត្រូវផ្អាក

**ខ្មែរប៉ុស្តិ៍ :** ព្រះរាជអាជ្ញាសាលាក្រុងភ្នំពេញ បានប្រកាសផ្អាកការចាប់ខ្លួនលោកស្រី មូរ សុខហួរ តែជ្រើសរកការដកហូតទ្រព្យសម្បត្តិរបស់លោកស្រីទៅវិញ ។

ការប្តូរឥរិយាបទនេះ អាចនឹងមកពីសំណាកសហគមន៍អន្តរជាតិ ដែលមានជាអាទិ លោកស្រី ណាវី ពីឡេ នៃគណៈកម្មាធិការជាន់ខ្ពស់របស់អង្គការសហប្រជាជាតិ ដែលបានស្តីបន្ទោសកម្ពុជាថា "កំពុងធ្វើឱ្យសិទ្ធិជាមូលដ្ឋានរបស់មនុស្សក្លាយជាវិចិរិលអស់..."! ការរិទានមកពីសម្ព័ន្ធអន្តរជាតិនៃសមជិកសភាដែលបាននិយាយថា "តុលាការកម្ពុជាមានឈ្មោះអាសោជន៍ **(តទៅទំព័រទី ១១)**



# ជួយជាវកាសែតដែលលោកអ្នកកំពុងអាន

ខ្មែរប៉ុស្តិ៍សូមអំពាវនាវដល់លោកអ្នកជួយជាវកាសែត "ខ្មែរប៉ុស្តិ៍" ប្រចាំឆ្នាំ គឺលោកអ្នកអាននឹងបានជួយដល់ហាគមន៍ខាងផ្នែកចំណេះដឹង និងទំនាក់ទំនង ។

បង់ប្រាក់ ៣០ ដុល្លារសម្រាប់ ៦ ខែ ឬ ៦០ ដុល្លារសម្រាប់១ឆ្នាំ លោកអ្នកនឹងបានទទួលនូវកាសែតយើងដល់ផ្ទះរបស់លោកអ្នក ហើយម្យ៉ាងទៀត លោកអ្នកបានជួយទ្រទ្រង់ដល់ដំណើរការរបស់ខ្មែរប៉ុស្តិ៍ ផងដែរ ៕





# ខួប ៦០ ឆ្នាំទំនាក់ទំនងកម្ពុជាសហរដ្ឋអាមេរិក







តំណាងសាខាគណបក្សប្រជាជនកម្ពុជាដឹកនាំដោយលោក សៀក សាន់ទី ព្រមទាំងសហការី បានអញ្ជើញចូលរួមអបអរសាទររំលឹកខួប៦០ រវាងសហរដ្ឋអាមេរិក និងប្រទេសកម្ពុជាក្នុងរដ្ឋវិជីន ញ៉ា កាលពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១០ កន្លងទៅ ។ លោកបណ្ឌិត kurt cam-bell ឧបការីរដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក ទទួលបន្ទុកកិច្ចការតំបន់អាស៊ីប៉ាស៊ីហ្វិក និងអាស៊ីខាងកើត បានសន្យានឹងបន្តមិត្តភាពកម្ពុជា និងសហរដ្ឋអាមេរិកអោយកាន់តែប្រសើរថែមទៀត ដើម្បីជំរុញលើវិស័យអប់រំ នយោបាយ សេដ្ឋកិច្ច យុទ្ធសាស្ត្រ និងអភិវឌ្ឍនៈនៅកម្ពុជា ។

កម្មវិធីរំលឹកខួប ៦០ នៃការបង្កើតចំណងមិត្តភាពរវាង កម្ពុជា និងសហរដ្ឋអាមេរិកនេះ គឺរៀបចំដោយលោក ហែម ហេង ឯកអគ្គរាជទូតកម្ពុជាប្រចាំសហរដ្ឋអាមេរិក និងសហការីរបស់លោក ។




នេះជាលើកទី១ហើយ ដែលកម្ពុជាមិនដែលបានធ្លាប់ធ្វើពិធីខួបរំលឹកមិត្តភាពការទូត រវាង កម្ពុជា និងសហរដ្ឋអាមេរិកទេ តាំងពីឆ្នាំ១៩៥០មក ។ ដោយក្នុងអំឡុងឆ្នាំ ១៩៥៦ ដល់ ១៩៧០ កម្ពុជាមានជំលោះការទូតជាមួយសហរដ្ឋអាមេរិក ហើយក៏បានអាក់ខានទំនាក់ទំនងគ្នា ( សម័យសង្គមរាស្ត្រនិយម ) ។

កម្ពុជាមានការទំនាក់ទំនងគ្នាក្នុងសម័យសាធារណរដ្ឋ ដែលដឹកនាំដោយលោកសេនាប្រមុខ លន់ នល់ ពីឆ្នាំ១៩៧០ ដល់ ១៩៧៥ ។ ការទំនាក់ទំនងគ្នានេះមិនបានប៉ុន្មានឆ្នាំផង ត្រូវបានកាត់ផ្តាច់ទាំងស្រុងដោយរបប ប៉ុល ពត ។ រហូតមកដល់ ឆ្នាំ១៩៩៣ បន្ទាប់ពីកម្ពុជាត្រូវបានរៀបចំអោយមានការបោះឆ្នោតដោយសេរី ប្រជាធិបតេយ្យ ពហុបក្ស ដែលដឹកនាំដោយអង្គការសហប្រជាជាតិនៅឆ្នាំ១៩៩៣ ទំនាក់ទំនងកម្ពុជាសហរដ្ឋអាមេរិក ចាប់មានភាពល្អប្រសើរបន្តិចម្តងៗ រហូតមកដល់បច្ចុប្បន្ននេះ ។ លោក ហែម ហេង បានមានប្រសាសន៍ថា ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ទំនាក់ទំនងរវាង កម្ពុជា សហរដ្ឋអាមេរិក មានភាពល្អប្រសើរណាស់ បើប្រៀបធៀបនាពេលកន្លងមក ។ លោក ហែម ហេង បានស្នើរសុំដល់រដ្ឋាភិបាលសហរដ្ឋអាមេរិក លើកលែងការយកពន្ធលើផលិតផលសំលៀកបំពាក់ដែលផលិត នៅស្រុកខ្មែរ នាំចូលមកលក់ក្នុងទីផ្សារសហរដ្ឋអាមេរិក និងលប់ចោលបំណុលដែលកម្ពុជាជំពាក់៣៥៨ ០០០ ០០០០ ដុល្លារ សហរដ្ឋអាមេរិកទាំងការ ទាំងដើមនោះផង ។

លោកបណ្ឌិត kurt cambell បានមានប្រសាសន៍ថា កម្ពុជាជាមិត្តដ៏ជិតស្និទ្ធ និងដ៏ល្អបំផុតរបស់សហរដ្ឋអាមេរិក ហើយយើង និងធ្វើអ្វីតាមលទ្ធភាពដែលយើងមាន ដើម្បីជួយអោយចំណងមិត្តភាពនេះកាន់តែល្អប្រសើរថែមទៀត ។


## KOCH INVESTIGATIONS & SECURITY SERVICES

2400 South 6th Street. Philadelphia, PA 19148
TEL. 215-380-5127

✓ យើងរក្សាសុវត្ថិភាពនៅ គោដនីយដ្ឋាន ហាងលក់ទំនិញតូចធំ
✓ ធ្វើការជូនពេលថ្ងៃធ្វើការ ពេលយប់នឹងចុងសប្តាហ៍
✓ ការពារដោយអាវុធ ឬក៏គ្មានអាវុធ
✓ តម្លៃថោកបំផុត





**Investigative Services**

- Undercover Investigations
- Embezzlement and fraud
- Surveillance, Video and Still Photos
- Criminal Investigations

**សេវាខាងស៊ើបអង្កេត**

- ស៊ើបអង្កេតជាសម្ងាត់
- ស៊ើបរឿងបន្លំលួចប្រាក់
- យាមតាមវីដេអូ និងតាមថតរូប
- ស៊ើបរឿងខាងឧក្រិដ្ឋកម្ម

**Security Services**

- Security Guards
- Executive Protection
- Personal Protection
- Doorman
- Security Audio/Video Equipment
- Computer Security

**សេវាខាងសុវត្ថិភាព**

- បុគ្គលិកខាងសន្តិសុខ
- បុគ្គលិកការពារថ្នាក់ដឹកនាំ
- បុគ្គលិកការពារផ្ទាល់ខ្លួន
- អ្នកយាមកាម
- សម្ភារៈការពារសុវត្ថិភាពដោយសម្លេង ឬរូបវីដេអូ
- មានលក់ និងដំឡើងសម្ភារៈកុំព្យូទ័រ

ការពារសន្តិសុខ ដែលទទួលការអនុញ្ញាតិពីក្រសួង ប៉ូលិស និងក្រសួងការពារក្រុងហ្វីឡាដែលហ្វៀ

សេវាគុណភាពខ្ពស់ ចេះប្រើភាសាខ្មែរ ភាសាចិន វៀតណាម និងឡាវ
"កុចស៊ើបអង្កេតនិងសុវត្ថិភាព"
ភាពខុសគ្នា គឺយើងយកចិត្តទុកដាក់ពីលោកអ្នក

OPERATION TOWN WATCH DIAL 911
PHILADELPHIA POLICE

វិភាគនយោបាយ

# អវត្តមានសម រង្ស៊ីជះឥទ្ធិពលធ្ងន់ធ្ងរដល់សម្លេងគាំទ្រនៃគណបក្សសម រង្ស៊ី

ដោយ : ចិន្តា, សុវណ្ណារា

•••អ្នកបោះឆ្នោតខ្មែរមានលក្ខណៈពិសេស និងខុសប្លែកពីអ្នកបោះឆ្នោតនៃប្រទេសមួយចំនួន ព្រោះអ្នកបោះឆ្នោតខ្មែរបោះឆ្នោតឱ្យគណបក្សនយោបាយដោយផ្អែកលើឈ្មោះ និងលក្ខណៈសម្បត្តិនៃមេដឹកនាំ (ប្រធាន) គណបក្សដោយមិនផ្តោតជាសំខាន់លើគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សឡើយ ។ រីឯអ្នកបោះឆ្នោតនៃបណ្តាប្រទេសមួយចំនួនពួកគេផ្តោតជាសំខាន់លើកគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សបន្ទាប់មកឈ្មោះ និងលក្ខណៈសម្បត្តិរបស់បេក្ខជន ឬមេដឹកនាំគណបក្ស ។

ជាការពិតមិនអាចប្រកែកបានសម្លេងឆ្នោតរបស់គណបក្ស សម រង្ស៊ី គឺទទួលបានមកដោយសារបុគ្គល សម រង្ស៊ី ព្រោះ សម រង្ស៊ី មានលក្ខណៈសម្បត្តិពិសេស និងអំណាចទាក់ទាញ (Charisma) ម្យ៉ាងវិញទៀត សម រង្ស៊ី តំណាងឱ្យសម្លេងប្រជាពលរដ្ឋ ដែលត្រូវបានគេជិះជាន់គាបសង្កត់ និងបំបិទសិទ្ធិសេរីភាពដែលមិនហ៊ាននិយាយចេញពីទុក្ខកង្វល់ក្នុងខ្លួនរបស់ពួកគេ ។ សម រង្ស៊ី ហ៊ានរិះគន់ និងប្រឈមជាមួយគូបក្ខដិបក្ខដ៏មានអំណាច និងឃោរឃៅ នេះជាលក្ខណៈសម្បត្តិពិសេសរបស់ សម រង្ស៊ី ។

យោងតាមការស្ទង់មតិសាធារណៈកម្ពុជា ដែលបានដឹកនាំធ្វើដោយវិទ្យាស្ថានសាធារណរដ្ឋអន្តរជាតិពីថ្ងៃទី 31 ខែកក្កដា ដល់ថ្ងៃទី26 ខែសីហា ឆ្នាំ2009 បានឱ្យដឹងថាសម្លេងគាំទ្ររបស់គណបក្ស សម រង្ស៊ី បានធ្លាក់ចុះពី 21,5% មកនៅត្រឹម17% ។ តាមការឱ្យដឹងការធ្លាក់ចុះភាគរយនៃសម្លេងគាំទ្រនេះទទួលរងនូវឥទ្ធិពលខ្លាំងពីអវត្តមានរបស់ សម រង្ស៊ី នៅកម្ពុជា ។ មន្ត្រីនៃវិទ្យាស្ថាននេះបានលើកឡើងក្នុងលក្ខខណ្ឌមិនបានបញ្ចេញអត្ត-សញ្ញាណថា ជាការពិតណាស់អវត្តមានរបស់ សម រង្ស៊ី




ក្នុងការដឹកនាំគណបក្សដោយផ្ទាល់បានបង្កើតឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងចំពោះសម្លេងគាំទ្រគណបក្ស ប៉ុន្តែនៅពេលជាមួយគ្នាសកម្មភាពចុះមូលដ្ឋានរបស់មន្ត្រីគណបក្សនេះ នៅមានកំរិត ហើយម្យ៉ាងវិញទៀតពួកគេប្រើ និងនិយាយភាសាដដែលៗ ដែលប្រជាពលរដ្ឋហាក់មានភាពជិនណាយនឹងស្តាប់ ។ អ្វីដែលសំខាន់ជាងនេះទៅទៀតនោះប្រជាពលរដ្ឋចង់ឃើញផលិតផលជាក់ស្តែងរបស់គណបក្ស សម រង្ស៊ី ដើម្បីបង្កើតឱ្យមានការជឿជាក់លើគណបក្សនេះស្របតាមទ្រឹស្តីគណបក្សនយោបាយ គឺ "ការមើលឃើញ និងការជឿ" ឬ "Seeing and Believing!" ។ មន្ត្រីនៃវិទ្យាស្ថាននេះបានប្រមាថាការធ្លាក់ចុះសម្លេងគាំទ្រនៃគណបក្ស សម រង្ស៊ី ជាសញ្ញាប្រកាសអាសន្នដ៏គ្រោះថ្នាក់មួយ ដូច្នេះគណបក្សនេះត្រូវរិះរកវិធីដោះស្រាយរកច្រកនយោបាយសម្រាប់ការវិលត្រឡប់របស់ សម រង្ស៊ី មកកាន់មាតុប្រទេសវិញ និងរៀបចំយុទ្ធសាស្ត្រ និងសារតែនយោបាយថ្មីសម្រាប់អ្នកគាំទ្រ និងប្រជាពលរដ្ឋទូទៅ ។

តាមការឱ្យដឹងសម្លេងរបស់គណបក្សសិទ្ធិមនុស្សបានកើនឡើងពី 8%ទៅ11% ។ នេះជាសញ្ញាវិជ្ជមានផ្នែកនយោបាយ និងការបោះឆ្នោតរបស់គណបក្សនេះ ។ ដោយផ្អែកលើកំណើនភាគរយនៃសម្លេងគាំទ្រនេះ កឹម សុខា ទំនងជាមិនជំរុញខ្លាំងប៉ុន្មានទេចំពោះការបង្រួបបង្រួមគ្នានេះ គឺគាត់គ្រាន់តែរុញទូកបណ្តោយទឹកតែប៉ុណ្ណោះ ។ បានន័យថា បើ សម រង្ស៊ី ចង់រួបរួមគាត់ក៏យល់ព្រម តែបើ សម រង្ស៊ី មិនចង់គាត់ក៏នៅស្ងៀមដែរ ។ បើទោះបីមានការរួបរួមគ្នា ក៏ កឹម សុខា មានទីតាំងនយោបាយល្អក្នុងការតថ្លៃជាមួយ សម រង្ស៊ី ផងដែរ ព្រោះសម្លេងគាំទ្ររបស់គាត់បានកើនឡើង ទោះបីតំណាងរាស្ត្ររបស់គាត់តិចជាង សម រង្ស៊ី ក៏ដោយ ។

ចំណែកគណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច និងជាតិនិយមបានបាត់បង់សម្លេងគាំទ្រពាក់កណ្តាលម្នាក់ ។ នេះជាសញ្ញាណានទៅរកការរលត់រលាយ ទោះបីគណបក្សទាំងពីរនេះបានខិតខំនៅពេលចុងក្រោយឈានទៅដល់ការបង្កើតសម្ព័ន្ធភាពក៏ដោយ ប៉ុន្តែទំនងជាមិនអាចជួយសង្គ្រោះជីវិតគណបក្សរាជានិយមនេះបានឡើយ ។

**•ដំណោះស្រាយនយោបាយសម្រាប់ សម រង្ស៊ី**

ស្ថិតក្នុងបរិបថនយោបាយបច្ចុប្បន្នដំណោះស្រាយនយោបាយសម្រាប់ សម រង្ស៊ី ហាក់នៅសល់បង្អួចតូចបំផុត ។ សម រង្ស៊ី កំពុងប្រឈមនឹងទៅទោសជាប់ពន្ធនាគាររយៈពេល2ឆ្នាំ តាមអំណាចសាលក្រមរបស់សាលាដំបូងខេត្តស្វាយរៀង កាលពីខែមករា ឆ្នាំ2010 ។ នៅពេលជាមួយគ្នា សម រង្ស៊ី បាននិងកំពុងប្រឈមនឹងបទចោទប្រកាន់ចំនួន3ករណីផ្សេងទៀត ដែលមេធាវីនៃរដ្ឋាភិបាល ហ៊ុន សែន ប្តឹង គឺ "ការក្លែងបន្លំឯកសារ ការប្រើប្រាស់ឯកសារក្លែងក្លាយ និងការផ្សាយព័ត៌មានមិនពិត" ។ ក្នុងករណីត្រូវបានផ្តន្ទាទោសតាមបទចោទទាំងនេះ សម រង្ស៊ី ត្រូវប្រឈមនឹងការជាប់ពន្ធនាគារពី៤ឆ្នាំទៅ 7ឆ្នាំ ។

រហូតមកដល់ពេលនេះ គេមិនទាន់ឃើញមានសញ្ញាណាមួយដែល ហ៊ុន សែន មានចេតនាបន្ធូរដៃចំពោះករណី សម រង្ស៊ី ឡើយ ។ កាលពីដើមខែមិថុនានេះចៅក្រមស៊ើបអង្កេតនៃសាលាដំបូងរាជធានីភ្នំពេញបានចេញដីកាបង្គាប់បញ្ជាឱ្យនគរបាលយុត្តិធម៌នាំខ្លួន សម រង្ស៊ី ចូលមកបំភ្លឺនៅតុលាការដោយផ្ទាល់បន្ទាប់ពី សម រង្ស៊ី បានខកខានបង្ហាញខ្លួនតាមដីកាកោះចំនួនពីរលើករួចមក ។ ហើយកាលពីពាក់កណ្តាលខែមិថុនាកន្លងទៅនេះសាលាឧទ្ធរណ៍បានសម្រេចតម្កល់ការសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញទាក់ទិននឹងសំណើរបស់មេធាវីការពារក្តីនៃ សម រង្ស៊ី ដើម្បីបង្កើតគណៈកម្មការព្រំដែនដែលមានសមាសភាពចម្រុះ ។ ទាំងនេះជាសញ្ញាអវិជ្ជមានផ្នែកនយោបាយថ្មីសម្រាប់ សម រង្ស៊ី ។

គេមិនសង្ឃឹមថា ការតស៊ូផ្លូវតុលាការរបស់ សម រង្ស៊ី នឹងទទួលបានជោគជ័យឡើយ ព្រោះបណ្តឹងប្រឆាំងនឹង សម រង្ស៊ី មិនមែនជាបញ្ហាច្បាប់ ប៉ុន្តែវាជាបញ្ហានយោបាយសុទ្ធសាធ ដែលមិនអាចដោះស្រាយតាមផ្លូវតុលាការបានឡើយម្យ៉ាងវិញទៀត សម រង្ស៊ី ខ្លួនឯងបានដឹងយ៉ាងច្បាស់ថា មិនអាចមានលទ្ធភាពយកឈ្នះលើ ហ៊ុន សែន តាមផ្លូវតុលាការបានឡើយ ព្រោះតុលាការ និងចៅក្រម-ព្រះរាជអាជ្ញា ស្ថិតនៅក្រោមការគ្រប់គ្រង និងបញ្ជារបស់ ហ៊ុន សែន ។ អ្នកវិភាគនយោបាយបានបញ្ចេញទស្សនៈថា វាជាការខាតបង់ពេលវេលាអត់ប្រយោជន៍សម្រាប់ សម រង្ស៊ី ក្នុងការចំណាយធនធាន និងពេលវេលាដើម្បីតស៊ូផ្លូវតុលាការ ពីព្រោះ សម រង្ស៊ី ធ្លាប់មានបទពិសោធន៍ឆ្លងកាត់ជាច្រើនលើករួចមកហើយ ហើយគាត់មិនដែលឈ្នះម្តងណាឡើយ ។ នៅទីបំផុត សម រង្ស៊ី ត្រូវបង្ខំឱ្យលះបង់ផ្លូវនយោបាយដើម្បីទទួលបានការលើកលែងទោសពីព្រះមហាក្សត្រ ។

នៅថ្ងៃទី3 ខែកុម្ភៈ ឆ្នាំ2005 សម រង្ស៊ី រត់ភៀសខ្លួនរស់និរទេសនៅក្រៅប្រទេសបន្ទាប់ពីត្រូវបានចោទប្រកាន់ពីបទបរិហារកេរ្តិ៍ និងបាត់បង់អភ័យឯកសិទ្ធិសភាជាមួយនឹងតំណាងរាស្ត្ររបស់គាត់ គឺ ជាម ចន្នី និង ជា ប៉ូច ។ ជាម ចន្នី ត្រូវបានចាប់ខ្លួន និងកាត់ទោសដោយ តុលាការយោធាពីបទបង្កើតកម្លាំងប្រដាប់អាវុធខុសច្បាប់ដាក់ពន្ធនាគាររយៈពេល 7ឆ្នាំ ប៉ុន្តែនៅ ខែកុម្ភៈ ឆ្នាំ2006 ជាម ចន្នី ត្រូវបានដោះលែងបន្ទាប់ពីព្រះមហាក្សត្រប្រោសព្រះរាជទានការលើកលែងទោស ។ សម រង្ស៊ី ត្រូវបានសាលាដំបូងរាជធានីភ្នំពេញកាត់ទោសកំបាំងមុខនៅថ្ងៃទី22 ខែធ្នូ ឆ្នាំ 2005 ដាក់ពន្ធនាគាររយៈពេល 18ខែ និងបង្គាប់ឱ្យបង់ប្រាក់ពិន័យចំនួន1ពាន់4រយដុល្លារ ។

នៅខែកុម្ភៈ ឆ្នាំ2006 សម រង្ស៊ី ទទួលបានការលើកលែងទោសតាមការស្នើសុំរបស់ ហ៊ុន សែន ទៅព្រះមហាក្សត្រ បន្ទាប់ពី សម រង្ស៊ី យល់ព្រមសុំទោស ហ៊ុន សែន ពីការដែលគាត់បានចោទប្រកាន់ ហ៊ុន សែន ថាជាអ្នកនៅពីក្រោយការគប់គ្រាប់បែកចូលហ្វូងបាតុកម្មនៅថ្ងៃទី30 ខែមិនា ឆ្នាំ1997 និងព្រមទទួលស្គាល់ថាការចោទប្រកាន់របស់គាត់មកលើ ហ៊ុន សែន កន្លងមកសុទ្ធសឹងតែជាការមួលបង្កាច់ទាំងអស់ ។ នេះជាការលះបង់នយោបាយដ៏ធំបំផុតវាប្រៀបបាននឹងការធ្វើអត្តឃាតនយោបាយដូច្នេះដែរ ។

នៅថ្ងៃទី25 ខែកុម្ភៈ ឆ្នាំ2008 រដ្ឋសភាបានបោះឆ្នោតព្យួរអភ័យឯកសិទ្ធិសភា សម រង្ស៊ី ដើម្បីបង្ខំឱ្យគាត់បង់ប្រាក់ពិន័យទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតពីបទបរិហារកេរ្តិ៍ដែលគាត់បានប្រព្រឹត្តនៅក្នុងអំឡុងពេលឃោសនាបោះឆ្នោត នាខែមិថុនា ឆ្នាំ2008 មកលើ ហ៊ុន សែន ។ អភ័យឯកសិទ្ធិសភារបស់ សម រង្ស៊ី ត្រូវបានប្រគល់ឱ្យវិញបន្ទាប់ពីគាត់យល់ព្រមបង់ប្រាក់ផាកពិន័យ ។

ករណីខាងលើជាការបង្ហាញអំពីសាវតានៃការតស៊ូផ្លូវតុលាការរបស់ សម រង្ស៊ី ប៉ុន្តែគាត់ពុំដែលមានសំណាងឈ្នះក្តីម្តងណាឡើយ ។

អ្នកវិភាគច្បាប់ និងនយោបាយបានលើកឡើងថា សម រង្ស៊ី មិនចាំបាច់ចំណាយពេលសម្រាប់ការតស៊ូផ្លូវតុលាការនោះទេ ព្រោះមជ្ឈដ្ឋានជាតិ និងអន្តរជាតិបានដឹងយ៉ាងច្បាស់ថា ប្រព័ន្ធយុត្តិធម៌នៅកម្ពុជាស្ថិតនៅក្រោមអំណាចឥទ្ធិពល និងការបង្គាប់បញ្ជារបស់ ហ៊ុន សែន ដូច្នេះ សម រង្ស៊ី មិនចាំបាច់ចំណាយពេលបង្ហាញឱ្យប្រជាពលរដ្ឋខ្មែរ ឃើញពីតថភាពនេះទៀតទេ ។

កាលពីពេលថ្មីៗនេះ រដ្ឋាភិបាលយួនបានឆ្លើយតបចំពោះការចោទប្រកាន់របស់ សម រង្ស៊ី ថា ប្រទេសយួនគោរពតាមផែនទីផ្លូវការ និងសន្ធិសញ្ញាបន្ថែមចុះឆ្នាំ 1984 និងឆ្នាំ2005 រវាងកម្ពុជា និងយួន ដូច្នេះប្រទេសយួនមិនបានរំលោភយកទឹកដីខ្មែរ ដូចការចោទប្រកាន់ឡើយ ។ នៅពេលជាមួយគ្នារដ្ឋាភិបាលយួននៅបានអះអាងថា ការកាត់ទោសប្រឆាំងនឹង សម រង្ស៊ី មិនត្រូវបានតុលាការកម្ពុជាធ្វើឡើងតាមការបញ្ជារបស់រដ្ឋាភិ-បាលយួនទើប

(តទៅទំព័រទី ១៧)

ក្រុមហ៊ុនទេសចរណ៍អន្តរជាតិ-អង្គរ
Angkor International Travel Agency




ទទួលផ្ញើរប្រាក់ទៅស្រុកខ្មែរ
សេវាលិខិតឆ្លងដែន

សេវាអន្តោប្រវេសន៍
កក់សណ្ឋាគារ ឬជួលឡាន

USA
4931 N. Old York Rd.
Philadelphia, Pa 19141
Tel: (215) 329-2036
Fax: (215) 329-7176
General Manager NARY PO
angkortravelphilly@yahoo.com

Cambodia Office: Victory Travel (Skin Belle)
No 57B, Eo Street 205 Touls Svay Prey 2.
Phnom Penh, Cambodia.
Ms. Chenda: 023-221069 * 012-851575
Or Mr. Sin Po: 012 429407 * 011-541111.
SERVING SINGAPOR, EVA AIR,
KOREAN AIRLINES, MALAYSIA etc...

# A.B.C MONEY TRANSACTION, INC

# $ ក្រុមហ៊ុនផ្ញើប្រាក់ A.B.C



## តម្លៃសំរាប់ផ្ញើទៅស្រុកខ្មែរ

| | | ភ្នំពេញ | តាមខេត្ត |
|---|---|---|---|
| ផ្ញើ $100 | យកកម្រៃ | $4.50 | $5.50 |
| $200 | យកកម្រៃ | $9.00 | $11.00 |
| $300 | យកកម្រៃ | $13.50 | $16.50 |
| $500 | យកកម្រៃ | $16.00 | $17.00 |
| $1000 | យកកម្រៃ | $25.00 | $26.00 |
| $1500 | យកកម្រៃ | $35.00 | $36.00 |
| $2000 | យកកម្រៃ | $42.00 | $43.00 |
| $2200 | យកកម្រៃ | $46.00 | $47.00 |

សូមកុំភ្លេចទាក់ទងការិយាល័យក្រុមហ៊ុន ABC ដែលនៅជិតលោកអ្នក ប្រសិនបើមានបំណងចង់ផ្ញើប្រាក់ទៅស្រុកខ្មែរ ឬក៏ទូរស័ព្ទមកយើងតាម

### នៅរដ្ឋ VIRGINIA សូមទាក់ទង

**ABC MONEY TRANSATION ,INC.**

8 locations to serve you in Virginia

- 6757 Willson Blvd.-Ste.#25 Tel : 703.534.2600
- 4291 Holland Rd-Ste.#111 Tel : 757.474.9400
- 10428 Ridgefield Pkwy Tel : 804-740-2454
- 2519 W . Mercury Blvd . Tel : 757.265.6305
- 23520 Overland Dr. Tel : 703.661.6666
- 6314 Rigsby Rd. Tel : 804.288.2988
- 7252 Arlingston Blvd . Tel : 703.641.0778
- 6217 W. Broad St. Tel : 804.288.6988

**ARIZONA**
- 4215 N 19th Ave. . Tel : 602.266.6744

**GEOERGIA**
- 4897 Buford Hwy. Ste. 202. Tel: 770.457.7888

**ILLINOIS**
- 4871 N. Broadway . Tel :773.989.7332

**MASSACHUSETTE**
- 996 Dorchester Ave. Tel:617.825.9380
- 1365-1377 Dorchester Ave. -Ste.4,Froor 1 . Tel : 617.265.4600

**MINNESOTA**
- 2718 Nicollet Ave . S.- Ste. 102 B Tel : 612.871.4731
- 6350 Brooklyn Blvd . Tel : 763.503.3947

**NORTH CAROLINA**
- 3000 Central Ave. Ste . #9 . Tel : 704-532-4420

**OREGON**
- 6908 N.E. Sandy Blvd . Tel : 503.281.8088

**PHILADFELPHIA**
- 5520 . Whitaker Ave. -Unit 2 . Tel : 215.831.9794
- 571 Adams Ave . Ave.#4 . Tel : 215.342.6623

**TEXAS**
- 1818 E . Pioneer Pkwy. Ste.156 . Tel : 317.461.1461
- 2615 W . Pioneer Pkwy. Ste.136 . Tel : 214.788.2817
- 5302 E . Belknap St.- Ste.D6 . Tel : 817.831.4836
- 3538 W . Walnut St. Tel : 972.272.2253
- 11205 Bellaire Blvd . Tel : 281.561.6600
- 10909 Scarsdale Blvd . Tel : 281.481.2700
- 13480 Veterans Memorial Dr.-Ste. F2. Tel: 281.587.0807

**WASHINTON STATE**
- 766 S.38th St,. Tel : 253.475.2847
- 3818 S.Graham St.-Ste. C Tel : 206.721.2070

## ក្រុមហ៊ុនទទួលផ្ញើប្រាក់ទៅកម្ពុជា

ABC ជាក្រុមហ៊ុនផ្ញើប្រាក់តែមួយគត់នៅស្រុកខ្មែរ ដែលមានការប្រគល់ប្រាក់ដល់ផ្ទះ

- ស្របច្បាប់
- រហ័សទាន់ចិត្ត
- ធានារ៉ាប់រង និងជូនប្រាក់ទៅដល់ផ្ទះ
- កំរៃផ្ញើថោកជាងកន្លែងដទៃ

### ក្រៅពីការផ្ញើប្រាក់ក្រុមហ៊ុនមានលក់

PHONE CARD និង PINLESS សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ ដែលផលិតដោយក្រុមហ៊ុន ABC ផ្ទាល់ មានគុណភាពល្អ ហើយជាពិសេស CARD របស់យើងនឹងទុកបានរហូត មិនអស់កំណត់កាលឡើយ ( NEVER EXPIRED) ។

ត្រូវការអ្នកសហការ (AGENTS ) ជាមួយយើងទូទាំងសហរដ្ឋអាមេរិក និងបានទទួលប្រាក់ចំណូលយ៉ាងខ្ពស់ !

ព័ត៌មានបន្ថែមសូមទាក់ទង CHET THACTHER តាមទូរស័ព្ទ និងអាស័យដ្ឋានខាងក្រោម :

Office : 714-590-8740 Fax : 714-590-8776
Cell: 714-603-3509 Toll Free : 1-877-939-0110

ABC MONEY TRANSATION, INC
12019 Garden Grove Blvd., Ste.#204
Garden Grove , CA 92843
chesterthatcher@yahoo.com

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ចេញផ្សាយថ្ងៃសុក្រ ទី២៣ ខែកក្កដា ឆ្នាំ២០១០

# Whither Asean Amid Region's Tensions and Growing Pains?

By Ian Williamson
THE CAMBODIA DAILY

Forty-three years after its birth, the Association of Southeast Asian Nations is now home to nearly 9 percent of the Earth's population, with a combined economic product last year of $1.5 trillion.

But does it mean anything to prisoners of conscience in Burma, refugees in Thailand or land protesters in Cambodia? Will it, like the European Union or the Organization of American States, remain relevant to regional development in the decades to come?

Speaking at a symposium in Phnom Penh yesterday on the future of US-Cambodian relations, Chheang Vannarith, executive director of the Cambodian Institute for Cooperation and Peace—one of several NGOs and think tanks affiliated with Asean—said he was "very doubtful" that Asean would continue to be a regional driving force in coming decades.

Mr Vannarith said that Asean's cumbersome decision-making process and policy of nonintervention in members' affairs stood in the way of decisive action in international events.

"Asean doesn't reform fast enough to stay relevant in regional security and regional economic mechanisms," he said. "Asean is very slow to react, especially when it comes to conflict resolution."

His comments coincided with the 43rd annual Asean Ministerial Meeting in Hanoi. Ministers from member countries met this week, and a series of related meetings are set to end today.

Prime Minister Hun Sen, along with other Asean heads of state, signed a declaration in March last year calling for the nations to form an integrated community by 2015. It specified three main areas of cooperation—economic, political security and socio-cultural.

Mr Vannarith added his voice to calls—first issued publicly by the Indonesian government in 2004—for Asean to maintain a peacekeeping force, to intervene in extreme cases where major human rights abuses are being committed.

"Asean promotes human rights but doesn't protect human rights," he said.

A Foreign Ministry spokesman declined to comment yesterday, saying Foreign Minister Hor Namhong was at the Asean meeting in Hanoi.

However, Ros Chantrabot, vice president of the Royal Academy of Cambodia, said Asean was designed to address matters of trade, not politics and democracy.

"Asean never considers politics and never interferes in other Asean members internal affairs," said Mr Chantrabot, who did not participate in yesterday's symposium. "Asean is solely focused on economics and business."


US Secretary of State Hillary Clinton, left, and Vietnam's Minister of Justice Ha Hung Cuong sign a memorandum of understanding for the US support of HIV/AIDS programs in Vietnam, at Ngoc Lam Pagoda in Hanoi yesterday. Clinton is in Hanoi for the Asean Regional Forum, which ends today.

"Asean feels that if economies and businesses expand, political issues and everything else will be resolved by themselves," he added.

In contrast to Asean, the governments of the EU were uniformly democratic and did not experience border disputes, he noted.

Asean members are currently monitoring the situation in Burma ahead of elections there later this year, Mr Vannarith said.

On Tuesday, Asean Secretary-General Surin Pitsuwan said Burma had received "an earful" regarding the forthcoming vote during the meetings in Hanoi, according to the news agency Reuters.

Asean has faced criticism in some quarters for not taking a tougher stand over the Burmese elections and has resisted calls for a public rebuke. Though terms of reference took effect last year, plans for an Asean human rights commission have been met with skepticism.

In April, Cambodia requested an urgent Asean summit on the escalating violence surrounding anti-government protests in Bangkok. The request was dismissed.

Given the Asean policy of nonintervention, Mr Vannarith said what was needed was a "soft interpretation and more flexible implementation" of those rules.

Mr Vannarith also criticized the organization's cumbersome decision-making process and advocated switching to a majority voting system. Asean currently requires all member states to agree on any proposal. Under such a system, deals "cannot be struck if one member state doesn't agree," he said.

Mr Vannarith said he felt the relationship between China and the US will be important to the future of Southeast Asia. The two superpowers "can be the main actors, working together in this region," he said.

He also said the US relationship with China was in the process of changing.

"US falling, China rising—that the status quo will be changed cannot be avoided," he said, though he did say that he felt it would be at least 40 or 50 years before China surpassed the US in terms of international influence and power.

*(Additional reporting by Neou Vannarin)*

# តើពេលមានភាពតានតឹងនិងការឈឺចាប់កើនឡើងអាស៊ាននៅឯណា ?

ដោយ Ian Willamson
THE CAMBODIA DAILY

រយៈពេល៤៣ឆ្នាំ បន្ទាប់ពីកំណើតខ្លួន សហគមប្រជាជាតិអាស៊ីអាគ្នេយ៍ ពេលនេះមានប្រជាជនចំនួនជិត៩ភាគរយនៃប្រជាជនលើពិភពលោកទាំងមូលជាមួយផលិតផលសេដ្ឋកិច្ចសរុបកាលពីឆ្នាំ មុនដែលមានទឹកប្រាក់ចំនួន ១.៥លានដុល្លារ ។

ប៉ុន្តែតើវាមានន័យអ្វីសម្រាប់អ្នកទោសមនសិការក្នុងប្រទេសភូមា ជនភៀសខ្លួននៅក្នុងប្រទេសថៃ ឬក្រុមអ្នកតវ៉ាដីធ្លីនៅទីនោះដែរឬទេ។ តើវានៅតែបន្តទាក់ទងនឹងការអភិវឌ្ឍន៍ក្នុងតំបន់ដូចសហភាពអឺរ៉ុប ឬអង្គការនៃបណ្ដារដ្ឋអាមេរិកក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ទៅមុខទៀតដែរឬទេ?

លោក ឈាង វណ្ណារិទ្ធ នាយកប្រតិបត្តិនៃវិទ្យាស្ថានកម្ពុជាសម្រាប់កិច្ចសហប្រតិបត្តិការ និងសន្តិភាពដែលជាអង្គការរដ្ឋាភិបាលមួយក្នុងចំណោមអង្គការក្រៅរដ្ឋាភិបាល និងក្រុមប្រឹក្សាយោបល់មួយចំនួនទៀត ដែលមានសម្ព័ន្ធភាពជាមួយអាស៊ាននោះ បានថ្លែងនៅឯសន្និសីទមួយក្នុងក្រុងភ្នំពេញ កាលពីម្សិលមិញស្ដីពីអនាគតនៃទំនាក់ទំនងរវាងអាមេរិក-កម្ពុជា ថាលោក "មិនគិត" ថាអាស៊ាននិងបន្តធ្វើជាកម្លាំងជំរុញនៅក្នុងតំបន់នៅប៉ុន្មានទសវត្សរ៍ទៅមុខទៀតនោះទេ ។ លោក វណ្ណារិទ្ធិ បានថ្លែងថា ដំណើរការធ្វើសេចក្ដីសម្រេចដែលមានបញ្ហារបស់អាស៊ាននឹងគោលការណ៍នៃការមិនធ្វើអន្តរាគមន៍ក្នុងកិច្ចការរបស់ប្រទេសជាសមាជិក គឺជាឧបសគ្គក្នុងព្រឹត្តិការណ៍អន្តរជាតិ។

លោកបានថ្លែងថា "អាស៊ានមិនបានកែទម្រង់ឱ្យបានលឿនល្មមដើម្បីបន្តក្នុងសន្តិសុខតំបន់និងយន្តការសេដ្ឋកិច្ចក្នុងតំបន់ទេ ។ អាស៊ាន យឺតយ៉ាវបំផុតក្នុងការបញ្ចេញប្រតិកម្ម ជាពិសេសទាក់ទិននឹងដំណោះស្រាយជម្លោះ "។

សេចក្ដីអត្ថាធិប្បាយរបស់លោកធ្វើឡើងគាប់ជួនជាមួយនឹងកិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានប្រចាំឆ្នាំលើកទី៤៣ នៅទីក្រុងហាណូយ ។ រដ្ឋមន្ត្រីនានាមកពីបណ្ដាប្រទេសជាសមាជិក បានជួបប្រជុំគ្នានៅសប្ដាហ៍នេះ ហើយកិច្ចប្រជុំដែលទាក់ទងជាបន្តបន្ទាប់ត្រូវកំណត់បញ្ចប់នៅថ្ងៃនេះ ។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន រួមជាមួយមេដឹកនាំអាស៊ានផ្សេងទៀត បានចុះហត្ថលេខាលើសេចក្ដីប្រកាសមួយក្នុងខែមីនាឆ្នាំមុន ដោយអំពាវនាវដល់បណ្ដាប្រទេសទាំងនេះឱ្យធ្វើការបង្កើតសហគមន៍រួមមួយត្រឹមឆ្នាំ២០១៥ ។ សេចក្ដីប្រកាសនេះបានបញ្ជាក់ថា វិស័យសំខាន់ៗចំនួន៣នៃកិច្ចសហប្រតិបត្តិការណ៍នោះ គឺសេដ្ឋកិច្ច ស្ថិរភាព នយោបាយ និងវប្បធម៌សង្គម។

លោក វណ្ណារិទ្ធ បានសំដែងការគាំទ្រចំពោះការអំពាវនាវដែលត្រូវបានចេញលើកទី១ជាសាធារណៈដោយរដ្ឋាភិបាលឥណ្ឌូនេស៊ីក្នុងឆ្នាំ២០០៤ ឱ្យអាស៊ានរក្សាកងកម្លាំងថែរក្សាសន្តិភាពមួយ អន្តរាគមន៍ក្នុងករណីធ្ងន់ធ្ងរពេលដែលការរំលោភសិទ្ធិមនុស្សសំខាន់ៗកំពុងត្រូវបានប្រព្រឹត្ត។

លោកបានថ្លែងថា"អាស៊ាន បានផ្សព្វផ្សាយពីសិទ្ធិមនុស្ស ក៏ប៉ុន្តែមិនការពារសិទ្ធិមនុស្សឡើយ"។

អ្នកនាំពាក្យម្នាក់របស់ក្រសួងការបរទេសបានបដិសេធមិនព្រមធ្វើអត្ថាធិប្បាយទេកាលពីម្សិលមិញ ដោយនិយាយថា លោក ហោ ណាំហុង រដ្ឋមន្ត្រីក្រសួងការបរទេសកំពុងស្ថិតនៅឯកិច្ចប្រជុំនេះនៅក្នុងទីក្រុងហាណូយ ។

ទោះជាយ៉ាងនេះក្ដី លោក រស់ ចន្ត្រាបុត្រ អនុប្រធានរាជបណ្ឌិតសភានៃកម្ពុជា បានថ្លែងថា អាស៊ានត្រូវបានបង្កើតឡើង ដើម្បីដោះស្រាយបញ្ហាពាណិជ្ជកម្ម មិនមែននយោបាយនិងប្រជាធិបតេយ្យទេ ។

លោក ចន្ត្រាបុត្រ ដែលមិនបានចូលរួមក្នុងសន្និសីទ នៅថ្ងៃព្រហស្បតិ៍នេះ បានថ្លែងតាមទូរស័ព្ទថា "អាស៊ានមិនដែលពិចារណាអំពីនយោបាយ និងមិនដែលជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់សមាជិកអាស៊ានផ្សេងទៀតឡើយ ។ អាស៊ានផ្ដោតតែលើសេដ្ឋកិច្ចពាណិជ្ជកម្មតែប៉ុណ្ណោះ ។ អាស៊ាន គិតថា ប្រសិនបើសេដ្ឋកិច្ច និងពាណិជ្ជកម្មរីកលូតលាស់បញ្ហានយោបាយ និងអ្វីៗផ្សេងទៀត និងរដ្ឋាភិបាលនានានៃសហព័ន្ធអឺរ៉ុប គឺជារដ្ឋាភិបាលប្រជាធិបតេយ្យដូចគ្នាទាំងអស់ ហើយមិនបានឆ្លងកាត់វិវាទព្រំដែនទេ ។

លោក វណ្ណារិទ្ធ បានថ្លែងថា សមាជិកអាស៊ាន បច្ចុប្បន្ននេះកំពុងតែសង្កេតមើលស្ថានភាពនៅក្នុងប្រទេសភូមាមុនការបោះឆ្នោតនៅឆ្នាំនេះ ។ កាលពីថ្ងៃអង្គារ លោក ស៊ូរិន ពិតស៊ូវ៉ាន់ អគ្គលេខាធិការអាស៊ានបានថ្លែងថា ប្រទេសនេះបានទទួល "ការស្ដីបន្ទោសមួយ" អំឡុងកិច្ចប្រជុំនៅក្នុងទីក្រុងហាណូយ នេះបើយោងទៅតាមទីភ្នាក់ងារព័ត៌មានរ៉យទ័រ ។

អាស៊ានកំពុងប្រឈមនិងការរិះគន់ខ្លះដោយសារមិនបានប្រកាន់ជំហរតឹងរឹងលើការបោះឆ្នោតនៅក្នុងប្រទេសភូមា ហើយបានជំទាស់នឹងការអំពាវនាវឱ្យមានការស្ដីបន្ទោសជាសាធារណៈមួយ ។ បើទោះជាលក្ខខណ្ឌនៃឯកសារយោងបានចូលជាធរមានកាលពីឆ្នាំមុនក៏ដោយ ក៏គម្រោងសម្រាប់គណៈកម្មការសិទ្ធិមនុស្សអាស៊ានមួយកំពុងទទួលបានការស្វាគមន៍ជាមួយនឹងការមន្ទិលសង្ស័យដែរ។

ក្នុងខែមេសា កម្ពុជាបានស្នើរឱ្យមានជំនួបកំពូលអាស៊ានជាបន្ទាន់មួយស្ដីពីអំពើហិង្សាដែលកាន់តែកើនឡើងជុំវិញការតវ៉ាប្រឆាំងរដ្ឋាភិបាលក្នុងក្រុងបាងកក។ សំណើរនេះត្រូវបានច្រានចោល។

ដោយសារនយោបាយអាស៊ាននៃការមិនអន្តរាគមន៍នោះ លោក វណ្ណារិទ្ធ បានថ្លែងថា អ្វីដែលចាំបាច់នោះគឺ "ការបកស្រាយដ៏ទន់ភ្លន់ និងការអនុវត្តវិធានការទាំងនោះ ប្រកបដោយភាពបត់បែនជាងគេ"។

លោក វណ្ណារិទ្ធ ក៏បានរិះគន់ផងដែរចំពោះដំណើរការធ្វើសេចក្ដីសម្រេចរបស់អង្គការនេះ និងបានគាំទ្រការផ្លាស់ប្ដូរទៅជាប្រព័ន្ធបោះឆ្នោតយកមតិភាគច្រើនវិញ ។ បច្ចុប្បន្នអាស៊ានតម្រូវឱ្យរដ្ឋសមាជិកទាំងអស់ព្រមព្រៀងលើសំណើរក៏ដោយ។ ក្រោមប្រព័ន្ធបែបនេះ កិច្ចព្រមព្រៀង "នឹងរាំងស្ទះប្រសិនបើរដ្ឋសមាជិកណាមួយមិនស្រប"។

លោក វណ្ណារិទ្ធ បានថ្លែងថា គាត់គិតថា ទំនាក់ទំនងរវាងប្រទេសចិន និងអាមេរិក និងមានសារៈសំខាន់ចំពោះអនាគតនៃអាស៊ីភាគអាគ្នេយ៍ ។ ប្រទេសមហាអំណាច២នេះ "អាចជាកត្តាដ៏សំខាន់ដោយធ្វើការរួមគ្នាក្នុងតំបន់នេះ"។ លោកបានថ្លែងថា ទំនាក់ទំនងរវាងអាមេរិកជាមួយចិន កំពុងស្ថិតក្នុងដំណើរការនៃការផ្លាស់ប្ដូរ ។

លោកបានថ្លែងថា "អាមេរិកដួលរលំ ចិនកើនឡើង នេះជាស្ថានការណ៍ដែលនឹងត្រូវផ្លាស់ប្ដូរមិនអាចចៀសផុតឡើយ "។ បើទោះជាលោកបានថ្លែងថា លោកគិតថា យ៉ាងហោចណាស់៤០ ឬ៥០ឆ្នាំទៀត ទើបចិនវ៉ាអាមេរិកទាក់ទងនិងឥទ្ធិពល និងអំណាចអន្តរជាតិក៏ដោយ ៕

*(រាយការណ៍បន្ថែម ដោយ : នៅ វណ្ណារិន)*

តើធ្មេញនេះអ្នកអាចញញឹមបានលេចធ្មេញ!










ពេទ្យថែរក្សាធ្មេញប្រចាំគ្រួសារ

FAMILY DENTAL CARE
AT
SMILE CARE CENTER
626 Snyder Avenue. Philadelphia, Pa 19148

យើងខ្ញុំអាចបកប្រែភាសាខ្មែរជូនលោកអ្នក សូមទាក់ទងជាមួយ ឈ្មោះ រីន ហេង និងជា លែនតាវ ដើម្បីណាត់ពិនិត្យ

WE SPEAK CAMBODIAN. PLEASE CONTACT :
MALY CHHORN & CHEALEN TAV 215-391-4100

**Children and Adults Welcome**

- Exams
- Root Canals
- Extractions
- Cleanings
- Braces
- Dental Implants

We accept all types of insurance including Medicare & Medicaid
PLEASE CALL TO MAKE YOUR APPOINTMENT TODAY !
(215) 391-4100

យើងទទួលយកគ្រប់ប្រភេទ អ៊ិនស្វ៊ីរ៉ង់ ដោយរាប់ទាំងម៉េឌីឃែ និងម៉េឌីឃេដ ផង សូមទូរស័ព្ទមកយើងខ្ញុំ នៅថ្ងៃនេះ ដើម្បីណាត់ពិនិត្យនូវលេខ **(215) 391-4100**

Penn Asian Senior Services
**PASSi**

**PASSi ជាសមាគមជួយចាស់ជរា និង ជនពិការ**

**សមាគមយើងខ្ញុំមានអ្នកថែរក្សាជាជនជាតិខ្មែរដែលអាចមកថែរក្សាចាស់ជរា និង ជនពិការ**

**សេវាកម្មឥតយកកំរៃផ្តល់ជូនអតិថិជន**

- មកជួបនៅគេហដ្ឋានតាមពេលកំណត់
- ជួយរៀបចំម្ហូបអាហារ និងការបរិភោគ
- ជួយរំលឹកពេលដែលត្រូវពិសារ និងប្រើប្រាស់ថ្នាំ
- ជួយក្នុងពេលងូតទឹក
- ជួយក្នុងការស្លៀកពាក់
- ជួយរៀបចំ និងសំអាតគេហដ្ឋាន
- ជួយបោក និងអ៊ុតសំលៀកបំពាក់
- មានអ្នកកំដរក្នុងការនិយាយលេង
- ជំនួយខាងផ្នែកអនាម័យ
- ជួយទិញម្ហូបអាហារ និងសំលៀកបំពាក់
- ជួយថែរក្សាសមាជិកក្នុងគ្រួសារ
- នៅមានជាច្រើនបន្ថែមទៀត



បើលោក លោកស្រីត្រូវការជំនួយសំរាប់សកម្មភាពរស់នៅប្រចាំថ្ងៃដូចបានរៀបរាប់ខាងលើនេះ សូមទាក់ទងមកលេខទូរស័ព្ទ **215-572-1234** ។
ម្យ៉ាងទៀត បើលោកអ្នកនាងដែលថែទាំមនុស្សចាស់ជរា ជាឪពុកម្តាយ ឬជីដូនជីតា នៅក្នុងបន្ទុក អាចនឹងទទួលប្រាក់បៀវត្សបានទៀតផង ។ សូមអរគុណ !

**DRANOFF ASSOCIATES**
*Attorneys at Law*



"ដ្រាណុហ្វ អាសូស៊ីយេត (DRANOFF ASSOCIATE ) គឺជាមណ្ឌលការពារតាមផ្លូវច្បាប់ ដែលធ្វើការប្រកបដោយភក្តីភាព ដើម្បីតំណាងឱ្យអ្នករងគ្រោះ ដែលមានរបួសរូបរាងកាយ ។

ស្ទីវិន ដ្រាណុហ្វ (STEVEN DRANOFF) គឺជាមេធាវីនៅសាលាក្តីមានបទពិសោធន៍យ៉ាងខ្ពស់ខាងសេវាច្បាប់ ៣៥ឆ្នាំ ។

យើងធ្វើការដោយយកកំរៃពីការងារដែលប្រគល់ឱ្យ លោកអ្នកមិនចាំបាច់ចេញថ្លៃចំណាយអ្វីមុននឹងលោកអ្នកទទួលប្រាក់សងពីមុខរបួសលោកអ្នកនោះទេ ។

ជំនួយខាងផ្លូវច្បាប់អាចផ្តល់ជូនជាភាសា ស្ប៉ានីស ខ្មែរ វៀតណាម កូរ៉េ និង ចិន ។

- **របួសលើរាងកាយ :** គ្រោះថ្នាក់រថយន្ត, ឡានឈ្នួល "សិបតា", ឡានត្រឹក, តាក់ស៊ី, ជិះកង់, ថ្មើរជើង, រអិលដួលលើទឹកកក, លើចិញ្ចើមថ្នល់ ឬក្នុងអាគារលក់ទំនិញ, គ្រោះថ្នាក់ដោយបានទិញរបស់ខូចមកប្រើ ឬក៏ឆ្កែខាំ... ។
- **ការប្រហែសក្នុងវិជ្ជាជីវៈ និងសិទ្ធិរបស់អតិថិជន :** ព្យាបាលតាមវិជ្ជាពេទ្យពុំបានត្រឹមត្រូវ, មរណភាពឥតសមហេតុផល, វាយមាយក្នុងការថែទាំមនុស្ស... ។

DRANOFF ASSOCIATES
121 South Broad Street, Suit 1210, Philadelphia, PA 19107
215-732-3333 (phone) 215-732-8059 (fax)
sdranoff@dranofflaw.com

# HONG KONG Super Market

FAMER´S BEST

Newly Renovated. Added new section .
Clean and Improved management !
ទើបនឹងកែលំអរថ្មីឡើងវិញ
-បន្ថែមផ្នែកលក់ថ្មីទៀត ហាងស្អាត ហើយបង្កើនគុណភាពគ្រប់គ្រង
**Weekly Sale** លក់ចុះថ្លៃរៀងរាល់សប្តាហ៍

**HONG KONG SUPERMARKET (PA) WEEKLY PROMOTION ITEMS**




571 ADAMS AVE.PHILADELPHIA, PA 19120
Tel : 215-7281300 Fax : 215-728-1600

**OPEN 7DAY 8:00-9:00**

- ចំណាយ $140 ដុល្លារ ទទួលបានអង្ករស្រូវស 25 ផោន
- ចំណាយ $100 ដុល្លារ ទទួលបានទូរភេសជ្ជៈ ឬមីកញ្ចប់មួយប្រអប់ ( តម្លៃ 8.99 )
- ចំណាយ $25 ដុល្លារ ទទួលបានទឹកសណ្តែកមួយដប ឬទឹកត្រីមួយដប ។

ឱសថស្ថាន ថាំងទី២

TANG PHARMACY II

HYUN TANG, PHARM. D.

FREE DELIVERY Locally

ថាំងឱសថស្ថាន សូមស្វាគមន៍

ថាំង ទទួលវេជ្ជបញ្ជា បន្ទុកថ្លៃប័ណ្ណ ចំពោះថ្នាំ (Generic Drug)

តម្លៃ $6.00 ចំពោះថ្នាំសំរាប់ ប្រើចំនួន ៣០ ថ្ងៃ

យើងមានថ្នាំចំនួន 500 មុខ ដែលមានគុណភាព ប្រសើរ ដូចថ្នាំមានឈ្មោះល្បី (Generic Drugs)

ឱសថស្ថានយើងមានទទួលយក Medicare, Medicaid និងInsurance គ្រោះថ្នាក់ចរាចរ និងគ្រោះថ្នាក់នៅកន្លែងធ្វើការនានា ។ លោកប្រុស និងអ្នកស្រី អាចទាក់ទងជាភាសាខ្មែរ ដោយកញ្ញា គីម ជូលី (បន្ទាប់ពីម៉ោង ១រសៀល) នៅឱសថស្ថានថាំង ទី២ សូមទាក់ទងហាងថ្នាំយើងខ្ញុំនៅអាស័យដ្ឋាន និងទូរស័ព្ទខាងក្រោម បើលោកអ្នកនៅមានចម្ងល់អ្វីមួយ ។



JULIE KIM, MANAGER

Contact After 1 p.m




Open: mon- Fri. 9a.m- 6p.m
Sat. 9 a.m - 3 p.m

5600 North. 5th Street. Philadelphia, PA 19120 Tel: (215) 224-3333 Fax: (215) 224-3363

## តមកទំព័រទី០១ ការឃាត់ខ្លួនលោកស្រី មូរសុខហួរ...

ដោយអំពើពុករលួយនឹងជាអ្នកបំរើឱ្យអ្នកមានអំណាច..."។

តែព្រះរាជអាជ្ញាខ្មែរ នៅពេលប្តូរឥរិយាបទបាននិយាយថា "តាមផ្លូវច្បាប់ការសងជម្ងឺចិត្ត គឺជាអាទិភាព គេត្រូវទុកពេលឱ្យចៅក្រមប្រើច្បាប់រដ្ឋប្បវេណី ដើម្បីបង្ខំឱ្យលោកស្រី មូរ សុខហួរ សងប្រាក់ឱ្យទាល់តែបាន..." មកទល់ពេលនេះ ចៅក្រម ជា សុឃៀង បានសរសេរលិខិតបញ្ជាការកាលពីថ្ងៃទី១៥ កក្កដា ២០១០នេះ ដើម្បីសុំឱ្យសភាជាតិបញ្ឈប់ការផ្តល់ប្រាក់បៀវត្សរ៍ជូនលោកស្រីសមាជិកសភារូបនេះរួចហើយ ។

លោកស្រី មូរស សុខហួរ បានត្រូវតុលាការខ្មែរពិន័យឱ្យបង់ប្រាក់ ១៦,៥លានរៀលត្រូវជា ៤,000 ដុល្លារសហរដ្ឋអាមេរិក ដោយសារតុលាការនេះ បានរកឃើញថា លោកស្រីបាននិយាយបរិហារកេរ្តិ៍លើរូបលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ៕

## តមកទំព័រទី០១ សកម្មភាពសហគមន៍ដោយរូបភាព...

ឬលក់ម្ហូបចំណី ដែលជាចំណូលចិត្តរបស់ខ្មែរទៀតផង ។ នេះ ជាគំរូដ៏ប្រសើរសម្រាប់កសាងសហគមន៍ខ្មែរឡើងវិញ ដោយការយកចិត្តទុកដាក់ខ្វល់ខ្វាយពីសុខភាពសហគមន៍ខ្លួន ៕





រូបថត វីរៈ សុវណ្ណ

## តមកទំព័រទី០៦ កុងស៊ុលខ្មែរនៅហ្វីឡានឹងបើកនៅខែកញ្ញា...

បើកមែនអាយុជីវិតនៃកុងស៊ុលនេះក៏មានមិនយូរអង្វែងឡើងព្រោះកុងស៊ុលតែឈ្មោះទេ ប៉ុន្តែធាតុពិតគឺ ស្នាក់ការសម្រាប់បំរើផលប្រយោជន៍ពួកកុម្មុយនិស្តតែប៉ុណ្ណោះ"។

សូមជម្រាបថា កុងស៊ុលខ្មែរនៅលើទឹកដីសហរដ្ឋអាមេរិក ត្រូវបានគេរាយការណ៍ថា ទើបតែមានពីរកន្លែងតែប៉ុណ្ណោះ ដោយទី១ ស្ថិតនៅទីក្រុង L.A តែត្រូវបានបិទទ្វារវិញបន្ទាប់ពីបើកបំរើសេវ៉ាកម្មបាន មួយដង្ហើមចង្រិតប៉ុណ្ណោះ ព្រោះបញ្ហាក្ស័យធន់។ បច្ចុប្បន្នកុងស៊ុលខ្មែរដែលកំពុងបំរើសេវ៉ាកម្មនានាដល់ពលរដ្ឋខ្មែរនោះ គឺស្ថិតនៅទីក្រុងឡូវែល នៃរដ្ឋម៉ាហ្សឈូសេត ដែលមានលោក អ៊ូ សុវណ្ណ ត្រូវទទួលតំណែងនេះយ៉ាងត្រជាក់ចិត្ត ។ រីឯនៅទីក្រុងឡុងប៊ិចនៃរដ្ឋកាលីហ្វ័រញ៉ា ត្រូវបានរាយការណ៍មកថា នៅមានគម្រោងបើកកុងស៊ុលខ្មែរដែរ ប៉ុន្តែកាលបរិច្ឆេទគេនៅពុំទាន់បានដឹងឡើយ ។ "ខ្មែរប៉ុស្តិ៍"ស្វាគមន៍ចំពោះវត្តមាននៃកុងស៊ុលខ្មែរថ្មីលើទឹកដីហ្វីឡាដែលហៀ្ប ក្នុងលក្ខខណ្ឌបំរើផលប្រយោជន៍ជាតិជាគោល ។ សង្ឃឹមយ៉ាងមុតមាំថា កុងស៊ុលថ្មីនេះពិតជាមានឆន្ទះបំរើដល់សេចក្តីត្រូវការរបស់ប្រជាពលរដ្ឋខ្មែរយ៉ាងពិតប្រាកដដោយមិនយករឿងនយោបាយមកឡូកឡំឡើយ ។

ព័ត៌មានថ្មីចុងក្រោយទាក់ទងនិងរឿងកុងស៊ុលខ្មែរនៅហ្វីឡានេះ "ខ្មែរប៉ុស្តិ៍"នឹងជម្រាបជូនមិត្តអ្នកអាននៅពេលក្រោយ ។ ក្នុងនេះផងដែរ "ខ្មែរប៉ុស្តិ៍" សូមស្វាគមន៍ចំពោះមិត្តអ្នកអានដែលចង់ចូលរួមចំណែកក្នុងការបញ្ចេញមតិយោបល់ទាក់ទងនិងប្រធានបទដូចបានជម្រាបខាងលើនេះ ៕

មានជំនាញខាងទិញ.លក់ផ្ទះ.ពាណិជ្ជកម្ម. វិនិយោគ ហិរញ្ញវត្ថុ ឬជួល
បើកស្វាគមន៍ចំពោះលោកអ្នកដែលធ្វើវិនិយោគ

Vinh Ho, 215-391-9516

Email: vho.realestate@consultant.com



ANCHOR Real Estate Development
320 Oregon Ave, #3B, Philadelphia, PA 19148

Specialize - Buy_Sell_Invest_Finance_Rent ...
Beginner-investors are welcomed!

ហាងជួសជុលឡាន អិន ខេ

NK AUTO

Free Estimate

5901 OXFORD AVENUE. PHILADELPHIA, PA 19149
TEL. 215-533-0163

ជួសជុលទូទៅនិងសោភកង់

បើមកធ្វើឡានតាមរយៈពាណិជ្ជកម្មនេះ នឹងទទួលបានបញ្ចុះតម្លៃពិសេស

General Repair & Tire Services
Mention this AD you will receive discount:





Inspection $35.00

Oil Change $20.00

Contact Vannak or Vanney 215-533-0163

# NEW GOLDEN PALACE

**SEAFOOD RESTAURANT**
**801-21 Washington Avenue.**
**Philadelphia, Pa 19147**

**Tel: 215-627-2822**

Business Hours: Monday–Sunday. 10 a.m.--10 p.m.

## សូមអញ្ជើញគ្រោងពិធីរបស់លោកអ្នកជាមួយនឹងយើងខ្ញុំ

*Plan your next event here!*



- *Wedding Reception* ●ពិធីមង្គលការ
- *Birthday Parties* ●បុណ្យខួបកំណើត
- *Business Meetings* ●ប្រជុំការងារជំនួញ
- *Private Parties* ●ពិធីជប់លៀងជាឯកជន
- *Fundraisers* ●បុណ្យរៃអង្គាសប្រាក់
- *We Accept Reservation for Holidays* ●យើងទទួលឱ្យកក់កន្លែងធ្វើពិធីនៅថ្ងៃឈប់បុណ្យទានបាន

## យើងបំរើម្ហូប ឌិម ស៊ុម រាល់ថ្ងៃ ពីព្រឹកដល់ល្ងាច



**We Serve Dim Sum Daily All Day Long &**



**Also Try Our Vietnamese Phở**

កុំភ្លេច ភ្លក់ "ហ្វើ" វៀតណាមរបស់យើង

**From 10 a.m. – 10 p.m.**

## ពិធីជប់លៀងល្ងាចពិសេស ជាមួយក្រុមគ្រួសារ

## ROYAL FAMILY DINNER PACKAGE

សំរាប់៦នាក់-ម្ហូប៧មុខ- **$78**
**DINNER FOR 6 - 7 Entrées $78**



1. **Vietnamese Spring Roll**
2. **Sweet Sour Pork Chops**
3. **Seafood Bean Curd Soup**
4. **Lobster with Ginger & Scallion**
5. **Steam Fish**
6. **House Special Fried Rice**
7. **Seasonal Fruit**

សំរាប់៨នាក់-ម្ហូប៨មុខ- **$98**
**DINNER 8 – 8 Entrées $98**

1. **Palace Appetizer**
2. **Shrimp Hot & Sour Soup**
3. **Baby Claims with Black Bean Sauce**
4. **Sautéed seafood with Chinese Vegetables**
5. **Lobster with Ginger & Scallion**
6. **Steam Fish**
7. **House Special Lo Mein**
8. **Seasonal Fruit**

សំរាប់១០នាក់-ម្ហូប៩មុខ- **$128**
**DINNER 10 – 9 Entrées $128**

1. **Fried Shrimp Rolls**
2. **Salt Baked Shrimp**
3. **Seafood with Sweet Corn Soup**
4. **Seafood Bird's Nest**
5. **Crispy Fried Chicken**
6. **Double Lobsters with Ginger Scallion**
7. **Steam/Fried Fish Tilapia**
8. **House Special Fried Rice**
9. **Seasonal Fruit**

# COMPUTER+ LLC

SURVEILLANCE SYSTEM, COMPUTER RETAILER, REPAIR & SERVICES



ជំនាញការងារជួសជុលកុំព្យូទ័រ លក់គ្រឿងកុំព្យូទ័រ
និងដាក់គ្រឿងថតវីដេអូសំរាប់ការពារសន្តិសុខ



REMOTE VIEWING

Remote Monitoring, Recording, Controlling through Internet from *anywhere* at *anytime*




**5709 N. 5th St., Phila, PA 19120** Open: *Mon-Sat; 10am—6:00pm*
Peter Hong Ching * Tel: (215) 276-7000 * Fax: (215) 276-7001
E-mail: peterchng_99@yahoo.com www.computerplusllc.com

# Nationwide

Insurance & Financial Service

## សេវាធានារ៉ាប់រង និងហិរញ្ញវត្ថុ

We offer Cheap Price for Every Client

## យើងធ្វើជូនគ្រប់ភ្ញៀវដោយតម្លៃថោក

| | |
|---|---|
| Business Liability Insurance | ធានារ៉ាប់រងជំនួញលោកអ្នក |
| Home Insurance | ធានារ៉ាប់រងផ្ទះសម្បែង |
| Health Insurance | ធានារ៉ាប់រងសុខភាព |
| Auto Insurance | ធានារ៉ាប់រងរថយន្ត |
| Life Insurance | ធានារ៉ាប់រងជីវិត |

Discount 30% when you purchase Home & Auto Insurance

ចុះតម្លៃ ៣០ % បន្ថែមបើលោកអ្នកទិញ
ធានារ៉ាប់រងផ្ទះ និងរថយន្តរួមគ្នា

South Philadelphia office:
600 Washington Ave Suite #8 Philadelphia, PA 19147
Tel: (215) 463-1257 , Fax: (215) 463-2036

ឌឹ ខេមបូឌា ដេលី The Cambodia Daily

# Police Seek More Suspects in Pagoda Pornography Scandal

By Khuon Narim
THE CAMBODIA DAILY



Authorities in Phnom Penh are seeking additional suspects in the sex scandal at Wat Sras Chak pagoda, where a defrocked monk was charged with making video recordings of more than 100 naked women while they bathed in holy water, according to Pong Savrith, deputy commander of military police in the capital.

"Now that we have slowed down the spread of the images of one of the victims on mobile telephones, we are continuing to investigate this crime for more suspects," said Mr Savrith.

Mr Savrith said that although the ex-monk, Neth Kai, claimed he had no accomplices, police suspect that others may have been involved both in filming the victims and in distributing one of the videos to mobile telephones.

Phnom Penh Municipal Court on Tuesday charged Neth Kai, who is accused of secretly filming more than 100 nude women at the pagoda since 2008, with producing and disseminating pornography under anti-human trafficking statutes, according to deputy prosecutor Ek Chheng Huot, who said that Neth Kai was in provisional detention at Prey Sar prison.

"I think that authorities will go on to arrest another suspect, because I do not believe that just one person could have produced so many films," said Chan Soveth, chief monitor at human rights group Adhoc.

Judge Chaing Sinat said that some of the women Neth Kai allegedly filmed had been identified as minors, which could potentially add years to any sentence.

"We have identified some of the victims as minors, which could mean added prison time for former monk Neth Kai," said Judge Sinat. "We appeal to all victims to file complaints against him so that we have more details."

# ប៉ូលិសកំពុងស្វែងរកជនសង្ស័យបន្ថែមទៀត អតីតសង្ឃ នេត ខៃ ក្នុងរឿងអាស្រូវ

ដោយ : ឃួន ណារីម
THE CAMBODIA DAILY

យោងតាមលោក ពង្ស សាវរិទ្ធ មេបញ្ជាការកងរាជអាវុធហត្ថក្រុងបានឱ្យដឹងថា ក្រុមអាជ្ញាធរនៅក្នុងទីក្រុងភ្នំពេញ កំពុងស្វែងរកជនសង្ស័យបន្ថែមទៀតនៅក្នុងរឿងអាស្រូវកេរខ្មាស់នៅវត្តស្រះចក ជាទីដែលអតីតសង្ឃ ដែលត្រូវបានផ្សឹក ត្រូវបានចោទប្រកាន់ពីបទថតរូបវីដេអូស្ត្រីអាក្រាតជាង ១០០នាក់ ខណៈដែលពួកគេបានងូតទឹកមន្ត ។

លោក ពង្ស សាវរិទ្ធ បានមានប្រសាសន៍ថា " ឥឡូវនេះយើងបានកាត់បន្ថយការសាយភាយរូបភាពជនរងគ្រោះតាមរយៈទូរស័ព្ទដៃ ហើយយើងកំពុងស្វែងរកជនសង្ស័យបន្ថែមទៀត "។

លោក ពង្ស សាវរិទ្ធ បានមានប្រសាសន៍ថា បើទោះណាជាអតីតសង្ឃ នេត ខៃ អះអាងថា ខ្លួនគ្មានអ្នកសំគំនិតក៏ដោយ ក៏ប៉ូលិសសង្ស័យថា ប្រហែលជាមនុស្សផ្សេងទៀតជាប់ពាក់ព័ន្ធទាំងនៅក្នុងការថតជនរងគ្រោះ និងការផ្សព្វផ្សាយរូបភាពវីដេអូទៅទូរស័ព្ទដៃដែរ។

យោងតាមលោក ឯក ឆេងហួត ព្រះរាជអាជ្ញារងតុលាការក្រុងដែលបានមានប្រសាសន៍ថា អតីតសង្ឃ នេត ខៃ ស្ថិតនៅក្នុងការឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងពន្ធនាគារនោះបានឱ្យដឹងថា កាលពីថ្ងៃអង្គារ តុលាការក្រុងភ្នំពេញ បានចោទប្រកាន់អតីតសង្ឃ នេត ខៃ នេះ ដែលត្រូវបានចោទប្រកាន់ពីបទថតរូបស្ត្រីអាក្រាតជាង១០០នាក់ ដោយសម្ងាត់នៅក្នុងវត្តនេះចាប់តាំងពីឆ្នាំ២០០៨ មកពីបទផលិតនិងចែកចាយរូបអាស់អាភាសតាមច្បាប់ប្រឆាំងការជួញដូរមនុស្ស។

លោក ចាន់ សុវ៉េត ប្រធានផ្នែកឃ្លាំងមើលនៃអង្គការសិទ្ធិមនុស្សអាដហុក បានមានប្រសាសន៍ថា "ខ្ញុំគិតថា ក្រុមអាជ្ញាធរនិងបន្តស្វែងរកចាប់ជនសង្ស័យម្នាក់ទៀត ពីព្រោះខ្ញុំមិនជឿថា មនុស្សតែម្នាក់អាចផលិតរូបដ៏ច្រើនបែបនេះកើតទេ" ។

ចៅក្រម ចាំង ស៊ីណាត បានមានប្រសាសន៍ថា ស្ត្រីមួយចំនួនក្នុងចំណោមស្ត្រីទាំងនោះ ដែលតាមចោទថា ត្រូវបានអតីតសង្ឃ នេត ខៃ ថតរូបនោះ ត្រូវបានរកឃើញថា ជាអនីតិជនដែលអាចបន្ថែមទោសជាប់ពន្ធនាគារជាច្រើនឆ្នាំ ។

ចៅក្រម ចាំង ស៊ីណាត ដែលមានប្រសាសន៍ថា "យើងបានរកឃើញថា ជនរងគ្រោះមួយចំនួននៅក្នុងចំណោមនៃជនរងគ្រោះទាំងនោះ ជាអនីតិជនដែលអាចមានន័យថា បន្ថែមរយៈពេលជាប់ពន្ធនាគារដល់អតីតសង្ឃ នេត ខៃ ។ យើងបានអំពាវនាវ ឱ្យជនរងគ្រោះទាំងអស់ប្ដឹងអតីតសង្ឃអង្គនេះ ដើម្បីឱ្យយើងមានព័តិមានកាន់តែច្រើន"៕

# អ្នកនយោបាយឬអ្នកលេងល្បែងនយោបាយ



ដោយ : រស់ ឃីន

•••ពាក្យពីរម៉ាត់នេះ ខ្ញុំយល់ថាមានន័យខុសគ្នា!

បើជាអ្នកនយោបាយពិតប្រាកដនោះ គឺជាអ្នកដឹកនាំជាតិឱ្យបានសុខសន្តិភាព-ប្រជាជនមានជីវភាពរស់នៅសុខស្រួលប្រកបដោយសុវត្ថិភាពគ្រប់យ៉ាង ។ នេះគឺជាអ្នកនយោបាយដែលមានមនសិកាជាតិ នឹងមានឆន្ទះហ៊ានប្ដូរស្លាប់ ប្ដូររស់ ដើម្បីជាតិរួចផុតពីខ្ញុំកញ្ជះបរទេស ។ អ្នកដឹកនាំមានគំនិតវិទ្យាសាស្ត្រ ដែលភាសាបារាំងហៅថា (Esprit Scientifique) គឺជាមនុស្សស្រឡាញ់សច្ចៈភាព (Amour de Vérité) ស្រឡាញ់ការពិត និងបោះបង់ចោលនូវអ្វីដែលជាការភាន់ច្រឡំ ហើយបំបាត់អ្វីជាមាយា ។ មនុស្សមានគំនិតរិះគន់ ដែលមិនស្របតាមអ្វីកើតឡើងតែសំបកក្រៅ ហើយស្វែងរកការពិតដោយប្រាថ្នាល្អិតល្អន់ប្រកបដោយសេរីកម្ម ។ ចេះសួរគេដើម្បីយល់ យល់ដើម្បីចេះ-ចេះដើម្បីដឹង។

អ្នកដឹកនាំល្អហ៊ានទទួលស្គាល់ហេតុការណ៍ដែលកើតឡើង រួចហើយយកហេតុការណ៍នោះ ជាប្រភពសម្រាប់ធ្វើបទពិសោធន៍ ថ្លឹងថ្លែងមើលពុទ្ធិគ្រប់យ៉ាង។

បើសិនជាយើងពិចារណាតាមដែលបានដកស្រង់គំនិតវិទ្យាសាស្ត្រខាងលើនេះ ហើយបើគិតតាំងពីឆ្នាំ ១៤៣២ ដែលខ្មែរយើងធ្វើចំណាក់ចំណោលក្រុងអង្គរ មកយើងឃើញថា ដូចជាមិនទាន់មានអ្នកនយោបាយពិតប្រាកដទេ ប៉ុន្តែសំបូរអ្នកលេងល្បែងនយោបាយ ។ ពាក្យចាស់លោកបានពោលថា មហាចំកូតបី ដែលច្រើនតែជ្រកនៅជាមួយនឹងអ្នកលេងល្បែងនយោបាយ គឺ ស្រី-ស្រា-ល្បែង។

អ្នកលេងល្បែងនយោបាយខ្មែរ ច្រើនតែលេងសន្លឹកបៀរ ដែលបរទេសជិតខាងឱ្យលេង។ ម្លោះហើយពួកគាត់ចាញ់ល្បែងនយោបាយលក់អស់-ទឹកដី-ព្រៃព្រឹក្សា។ បង្ហូរទាំងឈាមខ្មែរ ចាក់កៅឌី រហូតដល់ធ្លាក់ខ្លួន ជាប់ក្នុងអន្ទាក់សហព័ន្ធឥណ្ឌូចិន ត្រួតត្រាដោយយួនកុម្មុយនិស្ដហូ ជីមិញ ដេកក្នុងផ្នូរខ្មោចទៅហើយក្ដីក៏មហិច្ឆតារបស់វា នៅតែបញ្ជាកូនចៅវាឱ្យត្រួតត្រាក្បាលខ្មែរ និងឡាវទាល់តែបាន ។ ព្រោះថា មេដឹកនាំសុទ្ធតែអ្នកលេងល្បែងនយោបាយយ៉ាងណាមិញប្រទេសជិតខាងខ្មែរទាំងខាងលិច និងខាងកើតគេមិនរវល់នឹងជាតិសាសន៍ខ្មែរទេ គេមិនដែលប្រកាសយកខ្មែរជាសត្រូវឡើយ។ ប៉ុន្តែគេតែងទាក់យកមេ-មេខ្មែរគំរក់ធ្វើជាមិត្ត ហើយបង្ហាត់ឱ្យលេងល្បែងនយោបាយសម្លាប់ខ្មែរគ្នាឯង។

ប្រទេសជាមិត្តមកពីទិសខាងកើត ពូកែនាំខ្មែរលេង ល្បែងនយោបាយមែន!

រហូតទល់មកដល់ពេលនេះពាក្យថា បដិវត្តន៍រំដោះជាតិមួយ-អ្នកជាតិនិយមនេះពីរ-សាមគ្គីនេះបី-រត់ចូលព្រៃនេះបួន-វៀយួននេះប្រាំ ហាក់ដូចជាបានកាត់បន្ថយ ឬថាបានបាត់បង់អត្ថន័យទាំងស្រុង ពីអារម្មណ៍ជាតិខ្មែរស្រេចទៅហើយ។

នៅដល់តែពាក្យដែលពួកអាណានិគមស្រមោលធ្វើប្រជាភិថុតដូចជា : សេរីភាពប្រជាធិបតេយ្យ សេរីពហុបក្ស និងយុត្តិធម៌សង្គម អភិវឌ្ឍន៍ជាដើម ។ល។ ពាក្យទាំងនេះកំពុងបន្លំនៅរស់រវើកក្នុងវង់ អ្នកលេងល្បែងនយោបាយខ្មែរ ហើយបន្តតាមចាក់ល្បែងនេះទាល់តែវិនាសអស់លក់ទាំងកូនចៅចាក់ល្បែងនយោបាយបំផុតពូជតែម្ដង។

អឺចឹងទេ!!!ឃើញថា អ្នកនយោបាយដែលមានគំនិត្យវិទ្យាសាស្ត្រ និយម-ជាតិនិយម-ប្រជាធិបតេយ្យនិយម ហាក់បីដូចជាមិនជឿនលឿន ដូចអ្នកលេងល្បែងនយោបាយទេ នៅក្នុងប្រទេសសព្វថ្ងៃនេះ។

សូមពិចារណាលើទ្រឹស្ដី ខុងជឺ ដែលនិយាយថា:

១-ដើម្បីធ្វើឱ្យប្រទេសក្នុងសកលលោក មានសណ្ដាប់ធ្នាប់ល្អ ជាដំបូងត្រូវធ្វើឱ្យប្រទេសជាតិរបស់យើងមានសណ្ដាប់ធ្នាប់ល្អជាមុនសិន (To put the world in order we must first put the nation ordre)

២-ដើម្បីធ្វើឱ្យប្រទេសជាតិយើងមានសណ្ដាប់ធ្នាប់ល្អ ជាដំបូងយើងត្រូវធ្វើឱ្យគ្រួសារយើង មានសណ្ដាប់ធ្នាប់ល្អជាមុនសិន(To put the nation in order we must put the family in order)

៣-ដើម្បីឱ្យគ្រួសារមានសណ្ដាប់ធ្នាប់ល្អ ជាដំបូងយើងត្រូវតែបណ្ដុះជីវិតរស់នៅរបស់យើងឱ្យបានល្អជាមុនសិន(To put the family in order we must cul tivate our personal life)

៤-ហើយដើម្បីបណ្ដុះអប់រំធ្វើជីវិតយើងឱ្យបាន ល្អ ជាដំបូងយើងត្រូវតែរៀបចំ ធ្វើឱ្យចិត្តថ្លើមរបស់ យើងបានត្រឹមត្រូវជាមុនសិន(And to cultivate our personal life we must first set our hearts right) ។

សូមអំពាវនាវដល់បងប្អូនរួមជាតិ អស់លោក-លោកស្រី-កវី-បណ្ឌិត-ព្រឹទ្ធាចារ្យ ណាដែលបានស្គាល់អ្នកនិពន្ធរឿងធនញ្ជ័យ-អាឡេវ-អាចាក់ស្មុក-អាកំជិលផេះ-អាខ្វាក់អាខ្វិន សូមមេត្តាចែកចាយចំណេះដឹងផង។

( តមកពីទំព័រទី ០៣)

# រឿងព្រះគ្រូ ទឹម សាខន

សហព័ន្ធខ្មែរកម្ពុជាក្រោមកំពុងតែធ្វើកិច្ចការទូតនៅលើឆាកអន្តរជាតិក្នុងប្រធានបទ "ការសម្រេចជោគវាសនាខ្លួន ដោយខ្លួនឯង" ដើម្បីរំដោះសិទ្ធិសេរីភាពឱ្យដល់បងប្អូនខ្មែរកម្ពុជាក្រោម ឆ្ពោះទៅរកការនាំយកមកនូវសិទ្ធិស្វាយ័តដោយឯករាជ្យភាព ក្រោមមាគ៌ាអហិង្សាក្នុងគោលការណ៍ច្បាប់អន្តរជាតិនៅថ្ងៃអនាគត។ កាលពីថ្ងៃទី4 ខែមិថុនា ឆ្នាំ2010កន្លងទៅនេះ គឺជាខួបឆ្នាំទី6 នៃការបាត់បង់ទឹកដីកម្ពុជាក្រោមកូសាំងស៊ីន ដោយអាណានិគមនិយមបារាំងបានលួចកាត់ប្រគល់ឱ្យទៅយួននៅថ្ងៃ ទី4 ខែមិថុនា ឆ្នាំ1949 ។ ហើយចាប់ពីអំឡុងកាលនោះមកបងប្អូនខ្មែរកម្ពុជាក្រោមត្រូវទទួលរងនូវការធ្វើទុក្ខបុកម្នេញ ដោយគ្មានសេចក្ដីសុខក្នុងផ្លូវចិត្ត ផ្លូវកាយឡើយ ក្រោមការជិះជាន់សង្កត់សង្កិនគ្រប់សព្វយ៉ាងពីសំណាក់អាជ្ញាធរយួន ។

ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយក៏ការតស៊ូជីវិតទាំងទឹកភ្នែកស្រក់ជាប្រចាំ បងប្អូនខ្មែរកម្ពុជាក្រោមនៅតែបន្តការខិតខំជំនះរាល់ឧបសគ្គ យួនធ្វើមកលើពួកគេចំពោះរាល់ការបាញ់សម្លាប់ទ្រាំរស់វេទនានៅក្នុងគុកដើម្បីជាថ្នូរប្ដូរយកអត្តសញ្ញាណជាតិខ្លួន រក្សាឱ្យបានគង់វង់រហូតមកដល់សព្វថ្ងៃដែលជាការបង្ហាញឱ្យឃើញពីវីរភាព និងចក្ខុវិស័យស្នេហាជាតិមាតុភូមិ ដោយបងប្អូនខ្មែរកម្ពុជាក្រោមកំពុងអំពាវនាវស្រែកដង្ហោយហៅរកដោយសុំឱ្យពួកគាត់មានសេរីភាពសិទ្ធិនិយាយស្ដីប្រកបដោយក្ដីសុខសាន្តក្រោមច្បាប់នៃការគោរពសិទ្ធិមនុស្សអន្តរជាតិនោះ ៕

# អាថ៌កំបាំង និងសិល្បៈនៃជីវិត
# SECRET AND ART OF LIVING



***(តមកពីលេខមុន)***

**រៀបរៀងដោយ**
**លោក ម៉ៅ ច័ន្ទសំណុំ**

•អ្នកខ្លះយំ ពេលដែលតួអង្គធ្លាក់ដល់សភាពមហន្តរាយណាមួយ ហើយគេសើចហួរទឹកភ្នែកពេលជួបនឹងរឿងកំប្លែងម្តងៗ ។ រូបភាពប្រៀបធៀបនេះប្រហាក់ប្រហែលទៅនឹងការរៀបរាប់អំពីដី និងវត្ថុធ្វើអំពីដីខាងលើស្រាប់ ។ ដំបូងឡើយពន្លឺចេញពីអំពូលឃើញពុំឃើញមានរូបភាពអ្វីឡើយ វាជាវត្ថុធាតុដើមដំបូងដែលមានភាពពេញលេញ Formless, Absolute ។ លុះពន្លឺឆ្លងកាត់ហ្វីល ដែលប្រកបដោយរូបភាពអាត់ទុកពីមុនមក ពន្លឺនេះក៏បញ្ចាំងជារូបភាពទៅលើក្រណាត់សំពត់ស ។ ដូច្នេះ ពន្លឺដំបូងគ្មានអ្វីទាំងអស់បន្ទាប់មកដោយឆ្លងកាត់ហ្វីលវាក្លាយទៅជារូបរាប់ពាន់ ម៉ឺន សែន និងមានពណ៌ផង material form ។ ពន្លឺជាមូលដ្ឋានដំបូងចំបាច់មិនអាចខ្វះបាន Base and fundamental principle, and primary cause ពីព្រោះបើគ្មានវានោះ ក៏គ្មានរូបភាពដែរ ប៉ុន្តែអ្នកទស្សនា គេពុំបានចាប់ភ្លឹកនឹកនាដល់ពន្លឺឡើយ ដោយអារម្មណ៍របស់គេត្រូវស្រូបទៅក្នុងរូបភាពទាំងស្រុង ។ ម្យ៉ាងទៀតពន្លឺនេះថ្វីត្បិតតែយើងឃើញថាទទេគ្មានអ្វីសោះ ប៉ុន្តែវាបង្កប់រូបភាពរាប់លានក្នុងខ្លួនវានេះជាចរិកប្រកបដោយសក្តានុភាព Potentiality or possibility ។ ត្រង់នេះហើយខួរក្បាលពិបាកនឹងជឿពាក្យថា "ទទេ ប៉ុន្តែមានអ្វីទាំងអស់" (Empty but everything or empty is full – mystical language) ។

ពន្លឺនេះក៏មានចរិក អនន្ត Eternity វាវត្តមានក្នុងធម្មជាតិជានិច្ច ពុំមានទីចាប់ផ្តើម និងទីបញ្ចប់ ពុំមានកើត ពុំមានស្លាប់ ។ ជួនវាលេចឱ្យមនុស្សយើងឃើញ ។ ជួនយើងពុំឃើញវាទេ មនុស្សមានឧបករណ៍បញ្ចេញវាមកប្រើបានគ្រប់ពេល ដូចជាអំពូលភ្លើងជាដើម ។

ការលើកលំអិតចរិតលក្ខណៈរបស់ ទឹក ដី ពន្លឺ ខាងលើជាឧទាហរណ៍មកនេះ បុព្វបុរសមានបំណងឆ្លុះបញ្ចាំងសច្ចៈធម៌មួយមួយក្នុងធម្មជាតិរបស់កុង-ស្យនិស មនុស្សយើងនេះឯង។ កុងស្យនិសរបស់មនុស្សនេះ ជាផ្នែកមួយនៃធម្មជាតិ វាក៏មានចរិតលក្ខណៈដូច ទឹក ដី ពន្លឺ ដែរ មានន័យថា វាមានចរិតជាគូរៗ ដូចខ្ញុំអត្ថាធិប្បាយលំអិតកន្លងមកស្រាប់ ។

**(1) ចរិតដាច់ខាត និង "ដែលមានទំនាក់ទំនង"**
**Absolute and Relative :**

លោកអ្នកពិសោធជាក់ស្តែង រូបភាព លំហូរគំនិត ប្រតិកម្ម ការរំជួលចិត្ត ម៉េម៉ូរី និន្នាការ អាត្មា (Ego) ។ល។ ទាំងអស់នេះ សុទ្ធជារូបជាក់ស្តែងដែលយើងជាមនុស្ស ជាម្ចាស់ខ្លួនអាចដឹងតាមវិញ្ញាណទាំង៥បាន ។ វាទាំងអស់នេះមានចរិកប្រែប្រួលជានិច្ច មិនឋិតថេរ Transitory ចរិក "ដែលមានទំនាក់ទំនង" Relative ។ សូមពិនិត្យមើលចុះពីរយៈពេលមួយទៅរយៈពេលមួយទៀត គំនិតមនុស្សប្រែប្រួលប៉ុន្មានយ៉ាង ម្តងគិតឃើញដូច្នេះ ម្តងដូច្នោះ ប្រតិកម្មរាប់រយ រាប់ពាន់ ម៉ឺនយ៉ាងរាប់មិនអស់ ។ រូបភាពកើតឡើងហើយ ជាទារក កុមារ មនុស្សពេញវ័យ មនុស្សចាស់ស្លាប់ទៅវិញ ។

របស់មានរូបខាងលើ ដែលឃើញមើលឃើញដោយភ្នែក ដឹងតាមអារម្មណ៍ **មានគូររបស់វា** យ៉ាងពិតប្រាកដ ពុំប្រកែកបានឡើយ ។ ដៃគូររបស់វាគឺកុងស្យនិសបរិសុទ្ធនេះឯង ។ កុងស្យនិសបរិសុទ្ធនេះ គេអាចឱ្យឈ្មោះម្យ៉ាងទៀត គឺជីវិត ។ កុងស្យនិសបរិសុទ្ធ វាមានពិត វាជាបុព្វហេតុដំបូង ជាមូលដ្ឋានគ្រឹះនៃការកកើតឡើង ជារូបកាយ, គំនិត, ប្រតិកម្ម, ជាទំនោរម៉េម៉ូរី ។ ក៏ដូចឧទាហរណ៍អំពី ទឹកដី និងពន្លឺ បើមនុស្សយើងអស់ជីវិតភ្លាម តួអង្គមនុស្សប្រៀបដូចជាអង្កត់ឈើ គ្មានដង្ហើម សាច់ឈាមហើមស្តល់ គ្មានទេគំនិត អារម្មណ៍ ប្រតិកម្មអ្វីឡើយ ។ កុងស្យនិសបរិសុទ្ធ មានចរិកដាច់ខាត Absolute ។ យើងគ្រប់គ្នាមើល កុងស្យនិសបរិសុទ្ធនេះ ប្រៀបដូចជា កាំបិត ពុំអាចកាត់ខ្លួនវាបាន ឬប្រៀបដូចជាភ្នែកពុំអាចមើលខ្លួនវាបាន ។

**តើខ្ញុំជានរណា? Who am I?**

នេះជាសំនួរមួយមានលក្ខណៈមូលដ្ឋានបំផុតដែលមនុស្សជាតិរាប់ជំនាន់លើកឡើងក្នុងវិស័យសាសនា ក៏ដូចជាទស្សនវិជ្ជាបូរាណ និងសម័យ ។ សំនួរនេះអាចបំបែកជាលំអិត : តើខ្ញុំជារូបកាយនេះឬទេ? តើខ្ញុំជាចិត្តនេះ ឬជាអ្នកកំពុងតែគិតនេះ ឬជាអ្នកកំពុងតែខឹងនេះ ឬអ្នកកំពុងតែធ្វើការងារនេះ? តើខ្ញុំជានរណា? តើធម្មជាតិរបស់ខ្ញុំជាអ្វី? What is my true nature?

បើលោកអ្នករកឃើញចម្លើយនៃសំនួរនេះ (រកឃើញពុំមែនត្រឹមតែតាមរយៈខួរក្បាលត្រិះរិះប៉ុណ្ណោះទេ គឺមើលឃើញតាមរយៈការពិសោធជាក់ស្តែងក្នុងខ្លួន By intuition) លោកអ្នកបោះជំហានយ៉ាងវែងឆ្ពោះទៅកាន់តំបន់កុងស្យនិសបរិសុទ្ធ ទៅកាន់ទីរួចរំដោះពីទុក្ខសោកទាំងពួងក្នុងលោកដែលយើងកំពុងរស់នៅនេះ ។ ដើម្បីយល់សំនួរនេះបាន សូមតាមដានពិនិត្យរូបភាពប្រៀបធៀបដូចខាងក្រោម :

តើខ្ញុំជារូបភាពនេះឬ? តាំងពីកើតមក ខ្ញុំតែងគិតថាជារូបកាយនេះហើយ ។ បើពិនិត្យមើលរូបកាយនេះ វាផ្លាស់ប្តូរជានិច្ច ។ ដំបូងទារក កូនក្មេងពេញជំទង់ បុរស ហើយឥឡូវនេះមនុស្សចាស់អាយុ ៦ពឆ្នាំទៅហើយ ខ្ញុំជឿថាវានឹងស្លាប់ដូចមនុស្សនានាថ្ងៃមួយពុំខាន់ ។ ម្យ៉ាងទៀតរូបកាយនេះ គឺបានមកពីចំណីអាហារខ្ញុំបរិភោគ ។ បើខានហូបមួយរយៈ ច្បាស់ជារាងកាយនេះពុំនៅថេរទេ ។ ដូច្នេះរូបកាយនេះជាសំបកខាងក្រៅតែប៉ុណ្ណោះ ។ ដូចខ្ញុំបានជំរាបខាងលើស្រាប់ រូបកាយយើងមានចរិត " ដែលមានទំនាក់ទំនង" Relative វាពុំអាចឈរនៅម្នាក់វាបានឡើយ ។

ឥឡូវនេះ យើងចូលទៅក្នុងបន្ទិច ពិនិត្យពិភពនៃ


New World Travel II
ញូវឈ្រាវែលធូ

Specialized in Selling Flight Tickets
For National and International

ជំនាញខាងលក់សំបុត្រយន្តហោះសំរាប់ក្នុងប្រទេស និងអន្តរជាតិ យើងតំណាងឱ្យក្រុមហ៊ុន ចិន កូរ៉េ កាថេ ។ល។ ធ្វើលិខិត Re-Entry Permit ប្រញាប់ជូនបានទិញសំបុត្រជិះនាវាសមុទ្រ សណ្ឋាគារ ឬជួលឡាន សំបុត្រយន្តហោះទៅច្រើនប្រទេសក្នុងតម្លៃទាបបំផុត ។

Represented Several of Company such as China, Korea, Cathay etc.,
Offer Rush Re-Entry Permit
Reserve Cruise, Hotels and Car Rentals
Best Price Air Ticket for Many Destinations

600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036



ANGKOR AUTO SERVICE, INC.
ហាងជួសជុលរថយន្ត "អង្គរ"

4835 N. 16th Street.
Philadelphia, Pa 19141
Tel : (215) 455-7810
Ricky : (215) 485-1425

Specializing in Body Kit and Custom Paint
ជំនាញខាងជួសជុលតួរថយន្ត
និងបាញ់ថ្នាំដាក់ក្បាច់តាមបំណងភ្ញៀវ

RICKY
Hand Ph.: Ricky 215-485-1425

មានបទពិសោធន៍២០ ឆ្នាំ
ជាជាងរថយន្តមានសញ្ញាប័ត្រ
វាយតម្លៃការងារដោយឥតយកថ្លៃ
ហើយយើងជួយសន្សំប្រាក់តម្លៃ
បន្ថយរបស់អ៊ិនស្វ៊ិន បានផង
យើងផ្តល់សេវាគ្រប់យ៉ាង :
-State inspection
-Insurance Claims
-Auto Glass Repairs
-Auto Frame Repairs
-Custom Painting
-Auto A/C






បើកពីម៉ោង ៩ ព្រឹក
ដល់ម៉ោង៥ល្ងាច ពីថ្ងៃ
ច័ន្ទ ដល់ ថ្ងៃ សៅរ៍
ចុះតម្លៃជូន 10 % បើបង្ហាញបំណ្ណពាណិជ្ជកម្មនេះ

# ស្ត្រីខ្មែរដំបូងបង្អស់ដែលបានធ្វើដំណើរពីប្រទេសបារាំងមកភ្នំពេញតាមផ្លូវគោក



(តពីលេខមុន)

**ដោយ : ពិន នារីពិទូ**

•••ថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០០៦ : ជាមោទនៈភាពក្រៃលែងដែលយើងបានឆ្លងកាត់ចំងាយផ្លូវរាប់ពាន់គីឡូម៉ែត្រយ៉ាងវែង ពីទីក្រុងប៉ារីស រួចឈានជើងមកដល់ Tyumen ដែលស្ថិតតាមតំបន់ខ្ពង់រាបនៃជួរភ្នំអូរ៉ាល់នៃសាយប៊ីរ៉ុ (Syberia) ដូចសព្វដងពួកយើងបានចំណាយពេលដើម្បីដើរមើលទីក្រុងដែលលាតសន្ធឹងលើផ្ទៃដីធំល្វឹងល្វើយ ។ ប្រទេសរុស្សីសំបូរទៅដោយធនធានរ៉ែធម្មជាតិក្រោមដីដូចជា ឧស្ម័ន ប្រេងឥន្ធនៈ និងហ្គាស ដែលនាំចេញច្រើនជាងគេ ទៅតំបន់ផ្សេងៗក្នុងទ្វីបអឺរ៉ុប ប៉ុន្តែយើងបានប្រទះឃើញស្ថានីយ៍ប្រេង និង ហ្គាស នៅតាមផ្លូវជាតិធំៗតែប៉ុណ្ណោះ សំណាងល្អមានស្ថានីយ៍ប្រេងដែលមានចំងាយជាងដប់គីឡូម៉ែត្រពីទីក្រុង Tyumen ។ នៅតាមផ្លូវចូលនៃទីក្រុង ពួកយើងត្រូវបានត្រួតពិនិត្យដោយប៉ូលិសអស់រយៈពេល ១៥នាទីមុនពេលចេញដំណើរបន្តទៀត ប៉ូលិសរុស្សីនិយាយភាសាអង់គ្លេសបន្តិចបន្តួច និងពិបាកក្នុងការទំនាក់ទំនងគ្នា ។ ពួកគេបានពិនិត្យលើលិខិតស្នាម និងត្រាសណ្ឋាគារ ដែលស្នាក់នៅកន្លងមក ព្រមទាំងសួរថាតើអ្នកធ្វើដំណើរទៅណា? និងត្រួតពិនិត្យមើលទៅលើសុពលភាពនៃ Visa យ៉ាងយកចិត្តទុកដាក់ ក្រោយមកពួកយើងបានចាកចេញពីទីនោះដោយសុវត្ថិភាពមិនមានការបង់ប្រាក់អ្វីទាំងអស់។ យើងបានរកមើលសណ្ឋាគារតាមរយៈអ៊ិនធើណេត ដែលមានតំលៃថោកសមរម្យស្របតាមថវិការ ប៉ុន្តែមិនបានដូចបំណងព្រោះតំលៃបន្ទប់ជួលសុទ្ធសឹងតែថ្លៃៗ ។

ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៦ : ព្រឹកនេះយើងមានបំណងទៅទស្សនាព្រះវិហារ Trinity ប៉ុន្តែត្រូវខកខានដោយទីនោះ កំពុងជួសជុល។ នៅជុំវិញខ្លួនយើងមានអាគារចំរុះពណ៌ រីឯអាកាសធាតុវិញប្រែប្រួលពីត្រជាក់ទៅក្តៅយ៉ាងឆាប់រហ័ស ។

ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៦ : យើងបានចាកចេញពី Tyumen ក្នុងចំងាយ២៩២គីឡូម៉ែត្រ យើងបានមកដល់ Ishim នៅថៃ្ងរសៀលថៃ្ងដន្យយើងបានរកឃើញកន្លែងស្នាក់នៅដែលមានបន្ទប់ទំនេរ ព្រោះយើងមិនមានគំរោងត្រីវធ្វើ អ្វីនៅទីនេះនោះនៅឡើយក្រៅពីដើរកំសាន្តនៅក្នុងទីក្រុង ។

ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០៦ : យើងបានមកដល់ទីក្រុង Omsk ក្នុងចំងាយ៣២៥គីឡូម៉ែត្រ ពី Ishim ដែលនៅទិសនិរតីនៃសាយប៊ីរ៉ុ Siberia និងស្ថិតនៅភាគខាងកើតនៃជួរភ្នំអូរ៉ាល់ Ural ហើយក៏ជាទីក្រុងធំលំដាប់ទីពីររបស់ប្រទេសរុស្សី និងមានចំងាយពីទីក្រុងម៉ូស្គូ Moscow ២,៧០០គីឡូម៉ែត្រ។ មួយខែបានកន្លងផុតទៅបន្ទាប់ពីចាកចេញពីប្រទេសបារាំង នាថ្ងៃទី១ ខែសីហាមក ពួកយើងបានជំនះនូវឧបសគ្គជាច្រើនលើកក្នុងដំណើរឆ្លងកាត់ប្រទេសនិមួយៗ ហើយក៏ជាបទពិសោធន៍មួយយ៉ាងល្អ។ ទីក្រុងនេះមានផ្លូវគមនាគមន៍ស្អាតៗនិងចរាចរណ៍តិចតួចដែលបង្ករភាពងាយស្រួលក្នុងការបើកបរជាការកែរកំសាន្តពួកយើងក៏បានដើរមើលហាងលក់របស់របរប្រើប្រាស់ និងបានទិញទំនិញខ្លះៗ។



អូរេលី Aurélie និងស៊ីលវីយ៉ា Sylvia





ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០៦ : ថ្ងៃនេះក្នុងដំណើរឆ្ពោះទៅ Kuybychev ដោយមមាញឹកគួរសមពួកយើងក៏បានទៅកាន់ការិយាល័យប្រៃសណីយដើម្បីទូរស័ព្ទទៅភ្នាក់ងារទេសចរណ៍នៅទីក្រុង ពារនាដោយត្រូវចំណាយអស់២២យូរ៉ូ ស្របពេលនោះពួកយើងក៏បានទទួលលិខិតអញ្ជើញ ដើម្បីចុះបញ្ជី Visa ។ ពួកយើងនឹងបន្តរដំណើរ៣២៥ គីឡូម៉ែត្រទៀតដើម្បីទៅដល់ Kuybychev ដោយបើកបរអស់រយៈពេល ១៧ម៉ោង។ នៅតាមបណ្តាទីក្រុងទាំងឡាយ កន្លែងដែលងាយស្រួលក្នុងការប្រើប្រាស់អ៊ិនធើណេតក្នុងតំលៃថោក គួរតែនៅក្នុងការិយាល័យប្រៃសណីយ ។

(តទៅលេខក្រោយ)

From :Philadelphia



សួស្តីឆ្នាំថ្មី

ហាងខ្មែរជួសជុលរថយន្ត

បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ

**Rathe`s Auto Service**




State and Emission Inspection General Repairs and Maintenance

MON-SAT, 8:30AM -5:30PM
SUN. EMERGENCY ONLY

-ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
-មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
-មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ -មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : -ដូរប្រេងក៏រត ៥ ក្វាត $22. - INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ ពាក់-មានជូនប័ណ្ណពិសេស សំរាប់ដូរប្រេង ចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
-តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត
- ប្តេជ្ញាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ ។

ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL: (215) 329-2418
Fax: (215) 329-2419.Rath CELL: (215) 431-6376

Yes you can!

... get free or low-cost health insurance for your children.

- Did you lose your health insurance when you lost your job?
- Do your children have no health insurance?
- Do you wonder how you'll afford your kids' next doctor visit?

AmeriChoice
A UnitedHealth Group Company

(215) 360-9841
Leap Thach

Your children deserve to be healthy.
AmeriChoice can help.



# តមកទំព័រទី០១ អវត្តមាន សម រង្ស៊ី ជះឥទ្ធិពលធ្ងន់ធ្ងរ...

ប៉ុន្តែ សម រង្ស៊ី បានរំលោភច្បាប់ខ្មែរ ហើយត្រូវបានតុលាការខ្មែរកាត់ទោស ។ ការលើកឡើងរបស់រដ្ឋាភិបាលយួនត្រូវបានគេដឹងថា មានចេតនាលាងសំអាតខ្លួន ។ គេនៅចាំបានថា នាយករដ្ឋមន្ត្រីយួនបានលើកឡើងនៅក្នុងអំឡុងពេលទស្សនកិច្ចរបស់លោកស្រី ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រីប្រចាំការខ្មែរទៅកាន់ប្រទេសយួនថា ការដកបង្គោលតម្រុយព្រំដែនពីសំណាក់ សម រង្ស៊ី បានធ្វើឱ្យប៉ះពាល់ដល់ទំនាក់ទំនងល្អរវាងកម្ពុជា និង យួន ហើយវាជាទង្វើរិទ្ធង្សនា ។ នាយករដ្ឋមន្ត្រីយួនក៏បានស្នើតាមរយៈលោកស្រី ម៉ែន សំអន ដល់រដ្ឋាភិបាល ហ៊ុន សែន ឱ្យចាត់វិធានការផ្លូវច្បាប់ប្រឆាំងនឹង សម រង្ស៊ី ។ បន្ទាប់ពីការលើកឡើងរបស់នាយករដ្ឋមន្ត្រីយួនរដ្ឋាភិបាល ហ៊ុន សែន បាន ចាប់ផ្តើមដំណើរការនីតិវិធីច្បាប់ប្រឆាំងនឹង សម រង្ស៊ី ភ្លាម ។ នេះស្តែងឱ្យឃើញថា រដ្ឋាភិបាលយួនបានប្រើប្រាស់ឥទ្ធិពលរបស់ខ្លួនមកលើរដ្ឋាភិបាល ហ៊ុន សែន ដើម្បីប្រឆាំងនឹង សម រង្ស៊ី ។ យួនខ្ចីដៃរបស់ ហ៊ុន សែន ដើម្បីសម្លាប់ជីវិតនយោបាយរបស់ សម រង្ស៊ី ។

**•លទ្ធភាពនៃលក្ខខណ្ឌនយោបាយសម្រាប់ជាដំណោះស្រាយ :** អ្នកវិភាគនយោបាយបានលើកឡើងថាដំណោះស្រាយនយោបាយសម្រាប់ សម រង្ស៊ី អាចធ្វើទៅបានបើសិនជា សម រង្ស៊ី សុខចិត្តទទួលយកនូវលក្ខខណ្ឌនយោបាយចំនួនបីជាអាទិ៍: សម រង្ស៊ី ត្រូវទី1- សន្យាមិនបង្កើតសម្ព័ន្ធភាព ឬបង្កើតគណបក្សរួមជាមួយ កឹម សុខា ទី2- ឈប់និយាយពីបញ្ហាព្រំដែន និងអន្តោប្រវេសន៍យួននៅកម្ពុជា និងទី3- បញ្ឈប់ការវាយប្រហារមកលើមេដឹកនាំគណបក្សប្រជាជនកម្ពុជា ។ល។ ដូច្នេះបើ សម រង្ស៊ី ព្រមទទួល យកលក្ខខណ្ឌទាំងបីនេះដំណោះស្រាយនយោបាយសម្រាប់គាត់ក្នុងការវិលត្រឡប់មកកាន់មាតុប្រទេសវិញ ពិតជាកើតមានយ៉ាងឆាប់រហ័សបំផុត ។

ប៉ុន្តែអ្នកវិភាគនយោបាយបានព្យាករណ៍ទុកថា លក្ខខណ្ឌណាមួយដែល សម រង្ស៊ី ទទួលយកនោះសុទ្ធតែធ្វើឱ្យជីវិតនយោបាយរបស់ សម រង្ស៊ី និង គណបក្ស សម រង្ស៊ី ត្រូវបញ្ចប់ទាំងអស់ ។ សម រង្ស៊ី និងគណបក្សរបស់គាត់នឹងក្លាយជាគណបក្សរណប ឬគណបក្សអាយ៉ងរបស់ ហ៊ុន សែន ជាក់ជាមិនខានឡើយ ។

ដំណោះស្រាយនយោបាយតាមរយៈការដាក់សម្ពាធពីប្រទេសផ្តល់ជំនួយទំនងជាមិនមានប្រសិទ្ធភាពតទៅទៀតឡើយ ព្រោះប្រទេសផ្តល់ជំនួយហាក់បាត់បង់ការចាប់អារម្មណ៍លើតួនាទីគណបក្សប្រឆាំងនៅកម្ពុជាបន្ទាប់ពីការបោះឆ្នោតឆ្នាំ2008រួចមក ។ គេសង្កេតឃើញថាប្រទេសផ្តល់ជំនួយបរទេសមិនបានប្រើប្រាស់ឥទ្ធិពលជំនួយហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីធ្វើឱ្យរដ្ឋាភិបាល ហ៊ុន សែនទទួលស្គាល់តួនាទីនៃគណបក្សប្រឆាំងនៅក្នុងរដ្ឋសភាឡើយ ។ នៅពេលជាមួយគ្នាប្រទេសផ្តល់ជំនួយ និងសង្គមស៊ីវិលហាក់មិនសូវមានប្រតិកម្មស្រួចស្រាវចំពោះវិធានការច្បាប់ និងតុលាការប្រឆាំងនឹងតំណាងរាស្ត្រនៃគណបក្សប្រឆាំងនាពេលកន្លងមកទេ ។ ជាងនេះទៅទៀតបេសកកម្មការទូតនៃប្រទេសផ្តល់ជំនួយទាំងនោះត្រូវសហការជាមួយរដ្ឋាភិបាលនៃគណបក្សកាន់អំណាចដើម្បីនាំមកនូវការផ្លាស់ប្តូរ និងកំណែទម្រង់នៅក្នុងប្រទេសកម្ពុជា ។ ប្រទេសផ្តល់ជំនួយបរទេសមិនចង់បង្កើតសត្រូវជាមួយរដ្ឋាភិបាលនោះទេ ព្រោះគេត្រូវការសហជាមួយរដ្ឋាភិបាល ដើម្បីអនុវត្តគំរោង និងយុទ្ធសាស្ត្ររបស់គេ ។

អ្វីដែលប្រទេសផ្តល់ជំនួយអាចលើកឡើងជាមួយរដ្ឋាភិបាល ហ៊ុន សែន នោះ គឺការចង់បាននៃការបោះឆ្នោតប្រកបដោយភាពសេរី យុត្តិធម៌ តម្លាភាព លទ្ធិប្រជាធិបតេយ្យ និងការចូលរួមពីគ្រប់តួអង្គនយោបាយនៅកម្ពុជា ព្រមទាំងគោលការណ៍នៃទីលានប្រកួតប្រជែងនយោបាយដែលមានសមភាព ។ ការលើកឡើងនេះមិនមែនជាលក្ខខណ្ឌចាប់បង្ខំឡើយ ហើយវាអាស្រ័យលើរដ្ឋាភិបាល ហ៊ុន សែន ថាត្រូវអនុវត្តតាម ឬយ៉ាងណានោះ ។

**•ការបាត់បង់សិទ្ធិបោះឆ្នោតឈរឈ្មោះជាបេក្ខជននិងការដឹកនាំគណបក្ស :** យោងតាមច្បាប់បោះឆ្នោតកម្ពុជានៅពេលដែលសាលក្រមរបស់តុលាការចូលជាធរមាន សម រង្ស៊ី នឹងក្លាយជាទណ្ឌិត ដូច្នេះគាត់នឹងត្រូវបាត់បង់សិទ្ធិបោះឆ្នោត និងឈរឈ្មោះអោយគេបោះឆ្នោត (បេក្ខជន) ។ រីឯមុខតំណែងជាប្រធានគណបក្សរបស់ សម រង្ស៊ី ក៏អាចនឹងត្រូវបាត់បង់ផងដែរ ប៉ុន្តែច្បាប់ស្តីអំពីគណបក្សនយោបាយមិនបានចែងថា ទណ្ឌិតមិនមានសិទ្ធិដឹកនាំ ឬគ្រប់គ្រងអង្គការ សមាគម ឬគណបក្សបាននោះទេ ។ ប៉ុន្តែ ទោះបី សម រង្ស៊ី អាចបន្តធ្វើជាប្រធានគណបក្សបានក៏ដោយ ក៏មិនប្រាកដថា សម រង្ស៊ី អាចដឹកនាំគណបក្សដោយផ្ទាល់បានដែរ ព្រោះ សម រង្ស៊ី ត្រូវបំពេញកាតព្វកិច្ចទោសពន្ធនាគាររបស់គាត់នៅក្នុងពន្ធនាគារជាមុនសិន ។ សិទ្ធិរបស់ សម រង្ស៊ី អាចត្រូវបានស្តារនីតិសម្បទាឡើងវិញ តាមរយៈការបំពេញទោសចប់នៅក្នុងពន្ធនាគារ និងការលើកលែងទោសពីព្រះមហាក្សត្រ ។

ប៉ុន្តែការលើកលែងទោសអាចធ្វើទៅបាន លុះត្រាតែមានការគាំទ្រ និងស្នើសុំពី ហ៊ុន សែន ដែលចំណុចនេះចាំបាច់ត្រូវមានការសម្របសម្រួលផ្នែក នយោបាយរវាង សម រង្ស៊ី និង ហ៊ុន សែន ។ ថ្វីត្បិតតែរដ្ឋធម្មនុញ្ញកម្ពុជាបានចែងថាព្រះមហាក្សត្រមានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស ឬលើកលែងទោសដល់ទណ្ឌិតក៏ដោយ ប៉ុន្តែការអនុវត្តជាក់ស្តែងព្រះមហាក្សត្របច្ចុប្បន្នមិន ហ៊ានបន្ធូរបន្ថយទោស ឬលើកលែងទោសដល់បណ្ឌិតណាម្នាក់ដោយគ្មានការគាំទ្រ ឬស្នើសុំពីនាយករដ្ឋមន្ត្រី ហ៊ុន សែន ឡើយ ។

ហ៊ុន សែន បានប្រកាសឱ្យដឹងថា គាត់អាចស្នើសុំដល់ព្រះមហាក្សត្រដើម្បីប្រោសព្រះរាជទានការលើកលែងទោសដល់ សម រង្ស៊ី លុះត្រាតែ សម រង្ស៊ី បានបំពេញទោសពន្ធនាគារចំនួនពីរភាគបី (2/3) ជាមុនសិន ។ ការលើកឡើងរបស់ ហ៊ុន សែន បានខុសទៅនឹងបទពិសោធន៍កន្លងមក និងទិដ្ឋភាពច្បាប់បទពិសោធន៍កន្លងមក ហ៊ុន សែន បានស្នើទៅព្រះមហាក្សត្រប្រោសព្រះរាជទានលើកលែងទោសដល់អ្នកនយោបាយមួយចំនួនក្នុងនោះមានសម្តេចក្រុមព្រះ សម រង្ស៊ី, ញឹក ប៊ុនឆៃ សេរី កុសល, ជាម ចន្នី ។ល។ ដោយមិនរង់ចាំទណ្ឌិតទាំងនោះត្រូវបំពេញទោសពន្ធនាគារ 2/3ជាមុនសិនទេ ។

អ្វីដែល ហ៊ុន សែន លើកឡើងពីទិដ្ឋភាពច្បាប់ស្តីពីការបំពេញទោសចំនួន 2/3មុនអាចឈានដល់ការលើកលែងទោសពីព្រះមហាក្សត្រជាការយល់ច្រឡំអំពីព្រះរាជសិទ្ធិរបស់ព្រះមហាក្សត្រមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និងក្រឹត្យច្បាប់លេខ35នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាក្រឹត្យច្បាប់លេខ 35 ត្រូវបានគេប្រើប្រាស់សំរាប់តែការបន្ធូរបន្ថយទោស និងការលើកលែងទោសចំពោះទណ្ឌិតជាក្រុមដែលអាជ្ញាធពន្ធនាគារក្រសួងមហាផ្ទៃក្រសួងយុត្តិធម៌ ឬទីស្តីការគណៈរដ្ឋមន្ត្រីរៀបចំបញ្ជីស្នើមកព្រះមហាក្សត្រនៅក្នុងពិធីបុណ្យជាតិធំដូចជា បុណ្យភ្ជុំបិណ្ឌ ពិធីបុណ្យចំរើនព្រះជន្មព្រះមហាក្សត្រជាដើម ។ ប៉ុន្តែចំពោះទណ្ឌិតជាឯកត្តជនព្រះមហាក្សត្រមានព្រះរាជសិទ្ធិតាមរដ្ឋធម្មនុញ្ញប្រោសព្រះរាជទានការបន្ធូរបន្ថយទោស និងលើកលែងទោសតាមសំណើររបស់សាមីខ្លួន ឬក្រុមគ្រួសារ ឬមេធាវីការពារ ។

លោកស្រី សុខហួរ បានតស៊ូតាមផ្លូវតុលាការចំនួនបីថ្នាក់រួមទាំងតុលាការកំពូល ប៉ុន្តែលោកស្រីបានចាញ់ក្តីទាំងអស់ ។

គេនៅចាំបានថា លោកស្រី មូ សុខហួរ បានប្តឹង ហ៊ុន សែន ពីបទបរិហារកេរ្តិ៍ទាមទារសំណងជម្ងឺចិត្ត500រៀល ទាក់ទិនទៅនឹងការថ្លែងជាសាធារណៈ របស់ ហ៊ុន សែន សំដៅចំពោះស្ត្រីខ្មែរម្នាក់ដែលមិនបញ្ចេញឈ្មោះដោយប្រើពាក្យថា "ស្រីជើងខ្លាំង" ហើយថាស្ត្រីនោះបានប្រឡេះឡេវអាវខ្លួនឯង រួចប្តឹងចោទប្រកាន់គេឯង ។ លោកស្រី សុខហួរ បានចាត់ទុកថាសម្តីរបស់ ហ៊ុន សែន បាននិយាយចំពោះខ្លួនលោកស្រី ហើយលោកស្រីបានចាត់ទុកថាជាការមើលងាយ និងបរិហារកេរ្តិ៍មកលើលោកស្រី ។ ខណៈដែលបណ្តឹងរបស់លោកស្រី សុខហួរ ត្រូវបានដាក់ចូលដល់តុលាការ ហ៊ុន សែន ក៏បានដាក់ពាក្យបណ្តឹងតបតវិញដោយបានប្តឹងលោកស្រីពីបទ-បរិហារកេរ្តិ៍ ។



ក្រោយមកសាលាដំបូងរាជធានីភ្នំពេញ បានច្រានចោលពាក្យបណ្តឹងលោកស្រី សុខហួរ ដោយរក្សាទុកមិនចាត់ការ ហើយនៅពេលជាមួយគ្នា បានបន្តនីតិវិធីចំពោះបណ្តឹង ហ៊ុន សែន ប្រឆាំងនឹងលោកស្រី សុខហួរ វិញ ។ លទ្ធផលសាលាដំបូងរាជធានីភ្នំពេញ បានកាត់ទោសឱ្យលោកស្រី មូ សុខហួរ ចាញ់ក្តីហើយបានតំរូវឱ្យលោកស្រីបង់ប្រាក់សំណងខូចខាតចំនួន8លានរៀលចូលថវិការដ្ឋ និង8លាន5សែនរៀលទៀតឱ្យទៅ ហ៊ុន សែន ។ លោកស្រីបានបន្តប្តឹងឧទ្ធរណ៍ ប៉ុន្តែលោកស្រីបានចាញ់ក្តីជាបន្តបន្ទាប់ ។

គេសង្កេតឃើញថា នៅក្នុងឆ្នាំ2009កន្លងទៅនេះ ហ៊ុន សែន បានប្រើប្រាស់យុទ្ធសាស្ត្រវាយសង្គ្រប់មកលើគណបក្ស សម រង្ស៊ី ដោយយកអ្នកតំណាងរាស្ត្រ និងកាសែតគាំទ្រនៃគណបក្សនេះជាគោលដៅសំរាប់ការវាយបំបាក់ស្មារតី ។ តំណាងរាស្ត្រគណបក្ស សម រង្ស៊ី យ៉ាងហោចណាស់ចំនួន 3រូប គឺ ហូ វ៉ាន់ ត្រូវបានមន្ត្រីយោធាប្តឹងពីបទបរិហារកេរ្តិ៍, លោកស្រី មូ សុខហួរ ត្រូវបាននាយករដ្ឋមន្ត្រី ហ៊ុន សែន ប្តឹងពីបទបរិហារកេរ្តិ៍ និង សម រង្ស៊ី ត្រូវបានប្តឹងពីបទបំផ្លាញទ្រព្យសម្បត្តិសាធារណៈ ការក្លែងឯកសារសាធារណៈ និងផ្សព្វផ្សាយព័ត៌មានមិនពិត ។ រីឯចាងហ្វាងកាសែត2រូប គឺខ្មែរម្ចាស់ស្រុក និងមនសិការខ្មែរត្រូវបានប្តឹង និងចាប់ដាក់គុក ។

អ្នកវិភាគនយោបាយបានទស្សន៍ទាយថា ហ៊ុន សែន នឹងមិនបន្ធូរដៃឱ្យគណបក្ស សម រង្ស៊ី ទៀតឡើយ ព្រោះបច្ចុប្បន្ននេះ ហ៊ុន សែន មិន ភ័យព្រួយនឹងការផ្តាច់ជំនួយ ឬសម្ពាធនយោបាយ និងការទូតពីសហគមន៍អន្តរជាតិទៀតទេ ដោយហេតុថា គាត់មានមហាមិត្តចំនួន2រង់ចាំជួយដល់ការដឹកនាំប្រទេសរបស់គាត់ គឺចិន និងយួន ។ ម្យ៉ាងវិញទៀតឆ្លងតាមវេទិកាសហប្រតិបត្តិការជំនួយអភិវឌ្ឍន៍កម្ពុជារវាងរដ្ឋាភិបាល ហ៊ុន សែន និងដៃគូអភិវឌ្ឍន៍កម្ពុជាបានទទួលជំនួយផ្នែកហរិញ្ញវត្ថុចំនួន 1,100លានដុល្លាដែលចំនួននេះ បានកើនឡើងប្រមាណជា150លានដុល្លាច្រើនជាងឆ្នាំ2008 ប្រទេសផ្តល់ជំនួយបរទេសបានជ្រើសរើសការបន្តផ្តល់ជំនួយហិរញ្ញវត្ថុដល់រដ្ឋាភិបាល ហ៊ុន សែន ដើម្បីបន្តប្រើប្រាស់ឥទ្ធិពល និងលក្ខខណ្ឌជំនួយជំរុញឱ្យមានការផ្លាស់ប្តូរ និងកំណែទម្រង់តទៅទៀត ព្រោះថា ការផ្តាច់ជំនួយនឹងធ្វើឱ្យប្រទេសផ្តល់ជំនួយបាត់បង់ឥទ្ធិពលក្នុងការជំរុញរដ្ឋាភិបាលលើការផ្លាស់ប្តូរ និងកំណែទម្រង់ ។

ករណីរបស់លោកស្រី មូ សុខហួរ ហាក់មិនសូវធ្ងន់ធ្ងរប៉ុន្មាននោះទេ ព្រោះលោកស្រីមិនប្រឈមនឹងទោសពន្ធនាគារ ប៉ុន្តែសម្រាប់ សម រង្ស៊ី វិញ ត្រូវប្រឈមទាំងពីរ គឺទោសពន្ធនាគារ និងពិន័យជាប្រាក់ ។ ប៉ុន្តែលោកស្រី សុខហួរ? អាចប្រឈមនឹងការជាប់ពន្ធនាគារបង្ខំលើរូបរាងកាយក្នុងករណីលោកស្រីមិនព្រមបង់ប្រាក់ពិន័យ ។

លោកស្រី មូ សុខហួរ បានបង្ហាញពីឆន្ទៈមិនចុះញ៉មជាមួយ ហ៊ុន សែន ហើយក៏មិនទទួលយកសាលក្រមមានទោសរបស់តុលាការដែរ ។ លោកស្រី សុខហួរ បានប្តេជ្ញាដើរចូលគុកជាជាងការបង់ប្រាក់ពិន័យចំនួន 16,6លានរៀលទៅឱ្យ ហ៊ុន សែន និងរដ្ឋាភិបាលរបស់គាត់ ។ អ្នកវិភាគនយោបាយ បានលើកឡើងថា បើសិនជាលោកស្រី សុខហួរ សម្រេចចិត្តដូចគាត់អះអាងមែនវានឹងធ្វើឱ្យឈ្មោះរបស់លោកស្រីក្លាយជាវីរៈនារី ហើយអាចត្រូវបានគេតែងតាំងជាបេក្ខជនសម្រាប់ពានរង្វាន់សន្តិភាព ដូចលោកស្រី អ៊ុងសាន ស៊ូជី មេដឹកនាំនៃគណបក្សប្រឆាំងនៅប្រទេសភូមា អញ្ចឹងដែរ ។ ប៉ុន្តែកន្លងមកលោកស្រីបានទទួលពានរង្វាន់ជាច្រើនដូចជាពានរង្វាន់ខាងមេដឹកនាំស្ត្រីឈានមុខ និងការការពារស្ត្រី និងកុមារពីអំពើជួញដូរ ។ល។

ប៉ុន្តែអ្នកវិភាគនយោបាយបានប្រមានថា ការសម្រេចដើរចូលគុករបស់លោកស្រី សុខហួរ មិនមែនជាបច្ច័យល្អនោះទេ ។ លោកស្រីនឹងត្រូវបានបាត់បង់សេរីភាពបញ្ចេញមតិ និងសេរីភាពក្នុងការធ្វើសកម្មភាព និងធ្វើដំណើរ ។ លោកស្រីមិនអាចមានលទ្ធភាពធ្វើសកម្មភាពក្នុងការពង្រឹងគណបក្ស និងការពារផលប្រយោជន៍អ្នកបោះឆ្នោតនៅក្នុងមណ្ឌលរបស់លោកស្រី ។ នេះជាការខាងបង់ផ្នែកនយោបាយសម្រាប់គណបក្ស សម រង្ស៊ី ប៉ុន្តែលោកស្រីទទួលបានកេរ្តិ៍ឈ្មោះល្បីល្បាយសម្រាប់ខ្លួនលោកស្រីផ្ទាល់តែប៉ុណ្ណោះ ។ ចំពោះការសំរេចចិត្តរបស់គណបក្សសម្ព័ន្ធប្រជាធិបតេយ្យនៃលោកស្រី ស៊ូជី ដើម្បីធ្វើពហិការមិនចូលរួមការបោះឆ្នោតដែលរៀបចំដោយរដ្ឋាភិបាលផ្តាច់ការយោធាភូមាដែលជាលទ្ធផលគណបក្សរបស់លោកស្រីត្រូវបានរំលាយចោល ។ អ្នកវិភាគនយោបាយបានស្តីបន្ទោសថា ការសម្រេចចិត្តធ្វើពហិការជាការធ្វើដំណើរនៅផ្លូវនយោបាយមួយដែលខុសឆ្គង ព្រោះលោកស្រី ស៊ូជី បានផ្តល់ឱកាសដល់រដ្ឋាភិបាលផ្តាច់ការយោធាភូមាជិះសេះលែងដៃតែម្នាក់ឯងក្នុងការគ្រប់គ្រងអំណាច បើសិនជាគណបក្សរបស់លេកស្រី ស៊ូជី សម្រេចចូលរួមនៅក្នុងការបោះឆ្នោតនោះ គណបក្សនេះអាចដណ្តើមបានអាសនៈនៅក្នុងរដ្ឋសភាយ៉ាងហោចណាស់ជិតពាក់កណ្តាល ទោះបីមិនបានឈ្នះលើរដ្ឋាភិបាលយោធាភូមាក៏ដោយ ។ សម្លេងរបស់តំណាងរាស្ត្រនៃគណបក្សនេះអាចធ្វើឱ្យមានការប្រែប្រួល និងការផ្លាស់ប្តូរបានក្នុងរយៈពេលយូរអង្វែង ។ ម្យ៉ាងវិញទៀត អ្នកវិភាគបានលើកឡើងថា ប្រទេសនានាធ្វើការជាមួយរដ្ឋាភិបាល ទោះបីរដ្ឋាភិបាលកើតចេញពីការបោះឆ្នោតដោយសេរីនិងយុត្តិ ឬរដ្ឋាភិបាលលើកបន្ទុប និងឬមិនស្របច្បាប់ក៏ដោយ ។

លោកស្រី សុខហួរ បាននិងកំពុងចាប់ផ្តើមធ្វើយុទ្ធនាការស្វែងរកហត្ថលេខាភ្ជាប់ជាមួយញត្តិដើម្បីផ្ញើទៅលោក បារ៉ាក់ អូបាម៉ា ប្រធានាធិបតីនៃសហរដ្ឋអាមេរិក ។ លោកស្រីសង្ឃឹមថា លោក អូបាម៉ា ក្នុងនាមជាជ័យលាភីពានរង្វាន់សន្តិភាព និងជាប្រទេសផ្តល់ជំនួយមកកម្ពុជាផង នោះអាចដាក់សម្ពាធមកលើ ហ៊ុន សែន ឱ្យធ្វើការកែប្រែគោលជំហរ ។ ប៉ុន្តែអ្នកវិភាគយល់ផ្ទុយថា លោក អូបាម៉ា ទំនងជាមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់កម្ពុជាឡើយ ហើយ ទោះបីមានសម្ពាធពីលោក អូបាម៉ា ក៏ដោយ ក៏មិនប្រាកដថា ហ៊ុន សែន ទទួលយកដែរ ។ កាលពីពេលថ្មីកន្លងទៅនេះរដ្ឋាភិបាលសហរដ្ឋអាមេរិកបានប្រកាសព្យួរជំនួយយោធាជាប្រភេទយន្តយោធាជាង200គ្រឿង ដើម្បីឆ្លើយតបនឹងវិធានការរដ្ឋាភិបាល ហ៊ុន សែន ក្នុងការចាប់បញ្ជូនជនជាតិភាគតិចចិនអ៊ុយហ្គ័រចំនួន 20នាក់ ត្រឡប់ទៅប្រទេសចិន ។ ខណៈដែលអាមេរិកប្រកាសព្យួរជំនួយយោធា ប្រទេសចិនបានប្រកាសផ្តល់ជំនួយយោធាវិញ ដោយមានរថយន្តយោធាចំនួន250គ្រឿង និងឯកសណ្ឋានយោធាចំនួន5 ម៉ឺនកម្ពេ ។ ក្នុងករណីនេះ ហ៊ុន សែន មិនខ្វល់ ពីការដាក់ទណ្ឌកម្មជំនួយនោះឡើយ ព្រោះគាត់មានមហាមិត្តរង់ចាំជួយដល់គាត់ ។

បាល់ស្ថិតនៅក្នុងជើងរបស់លោកស្រី មូ សុខហួរ ថាតើគាត់ត្រូវទាត់វា ឬទុកវា ? ៕




Think of life insurance from New York Life as a gift of financial protection. With cash value that increases every year,* even in times like these, your whole life policy can help fund a college education, pay off debts, or let you plan for the unexpected.† And what's more, it's backed by the highest possible ratings for financial strength.‡ Give your family the most selfless gift of all, a secure financial future.

NEW YORK LIFE

Concerned about your family's future? Talk to your New York Life agent today.

Pom Srey
Agent

**New York Life Insurance Company**
100 Witmer Road Suite 100
Horsham, PA 19044
(215) 441-6280
psrey@ft.newyorklife.com

THE COMPANY YOU KEEP®
www.newyorklife.com

*As premiums are paid. †The cash value in a life insurance policy is accessed through policy loans, which accrue interest at the current rate, and cash withdrawals. Loans and withdrawals will decrease the death benefit and cash value. ‡Standard & Poor's (AAA), A. M. Best (A++), Moody's (Aaa) and Fitch (AAA) for financial strength. Source: Individual Third Party Ratings Reports (as of 6/16/09). © 2009 New York Life Insurance Company, 51 Madison Avenue, New York, NY 10010

100121 AGY-1250 00398624 CV 6/11

Sav-Mor PHARMACY
Tel: 215-467-1220

# ឱសថស្ថានខ្មែរ

Sav-Mor PHARMAC

Sam EA R.Ph.

2232 S. 7th St. (7th & Wolf) Philadelphia, Pa 19148
Tel: 215.467.1220 Fax: 215.467.1447



## បំរើលោកអ្នកដោយមិត្តភាព និងទាន់ចិត្ត

▸▸ Sav Mor គឺជាឱសថស្ថានបំរើការចែកចាយថ្នាំ ហើយអាចពន្យល់ពីរបៀបប្រើប្រាស់ថ្នាំតាមវេជ្ជបញ្ជា ជាភាសាខ្មែរបាន យើងទទួលយកនូវ MEDICARE MEDICAID និង INSURANCES ជាច្រើនទៀតផង យើងមានលក់កាត់សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ និងអន្តរជាតិ

*Accept most insurance plans including Medicare & Medicaid
*Easy Prescription transfer
*Inside. Prepaid phone card. Call Cambodia.

# FOR SALE BY OWNER

HASS´S AUTO ជួសជុលតួឡានដែលបុគ្គលម្ចាស់ហាងចូលនិវត្តន៍-ហាងមានដំណើរការ១៧ឆ្នាំមកហើយ-ពាណិជ្ជកម្មមានលំនឹងល្អគ្រប់រដូវលោកអ្នកអាចទិញតែពាណិជ្ជកម្មក៏បាន-ទិញដីជាមួយនឹងផ្ទះក៏បាន-ទិញទាំងពីររួមគ្នាក៏បាន បើចង់ដឹងច្បាស់សូមទូរស័ព្ទរកឈ្មោះ "នីក"

Owner is retiring. 17 years in business at this location. Well established business, all seasons are busy. Option to buy only business, real estate, or both.




Contact Nick: 267-242-7938
615 W. Fisher Ave. Phila, Pa 191203

# Danny's Café




Foods & Hoagies

1. Beef Stew Serve with Bread.......................នំប៉័ងខគោ
2. Curry Chicken Serve with Bread...............នំប៉័ងការីសាច់មាន់
3. Curry Beef Saramann Serve with Bread....នំប៉័ងសាច់គោ ខការីសារាម៉ាន់
4. Meatball Soup Serve with Bread ..............ស៊ុបប្រហិតជាមួយនំប៉័ង
5. Mi Siam ..................................................មីសៀម







1730 Snyder Ave, Philadelphia, PA 19145 / Mon – Fri: 7am – 7pm Saturday: 9 am – 8 pm / Sunday : CLOSED
Tel: 215.467.4082 Fax: 215.467.4642 / Thank You, Please come again !

# FRANK'S TIRES




2654 S. FAIRHILL ST.
(215) 334-2261
OPE N 7 DAYS A WEEK
8 A.M. – 7 P.M.

NEW & USED TIRES
ESTBLISHED SINCE 1984

*Totally Traditional!*
*Totally Cambodielicious!*




# KAVEI CAMBODIAN RESTAURANT

Authentic Khmer • Thai • Lao • Vietnamese Phở

320 W OREGON AVENUE
(OREGON MARKET, SOUTH PHILLY)

215.952.6688

OPEN 7 DAYS A WEEK
9am-10pm